# ការសិក្សាវាយតម្លៃអាណត្តិទីពីរ
# នៃកំណែទម្រង់វមជ្ឈការនៅកម្ពុជា៖






## ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ និង
## ការចូលរួមរបស់ប្រជាពលរដ្ឋ
## ២០០៧-២០១២





COMFREL

កុម្ភៈ
២០១៣

# ការសិក្សាវាយតម្លៃអាណត្តិទីពីរ
# នៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា៖

*ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ និងការចូលរួមរបស់ប្រជាពលរដ្ឋ ២០០៧-២០១២*

*កុម្ភៈ ២០១៣*

# មាតិកា


អំពីអក្សរកាត់ និងពាក្យបំព្រួញ ..... i

សេចក្តីថ្លែងអំណរគុណ ..... iii

១. សេចក្តីផ្តើម ..... ១

២. សេចក្តីសង្ខេប ..... ៣

៣. ប្រវត្តិនៃការបោះឆ្នោតឃុំ សង្កាត់ និងវិមជ្ឈការ ..... ៥

៤. ស្ថានភាពបច្ចុប្បន្ន ..... ៦

៥. ការពិនិត្យមើលដំណើរការកំណែទម្រង់បញ្ហាចម្បង និងប្រឈម : ..... ៨

៥.១ វិមជ្ឈការនយោបាយ ..... ៨

៥.២ វិមជ្ឈការរដ្ឋបាល ..... ១២

៥.៣ វិមជ្ឈការហិរញ្ញវត្ថុ ..... ១៣

៥.៤ ក្របខ័ណ្ឌច្បាប់ និងយន្តការគាំទ្រកំណែទម្រង់វិមជ្ឈការ ..... ១៥

៥.៤.១ ក្របខ័ណ្ឌច្បាប់ ..... ១៥

៥.៤.២ យន្តការគាំទ្រកំណែទម្រង់វិមជ្ឈការ ..... ១៧

៦. ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ ..... ១៨

៦.១ គណនេយ្យភាព ..... ១៩

៦.២ ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ..... ២១

៦.៣ ការដោះស្រាយជម្លោះ និងបញ្ហា ..... ២៣

៦.៤ ទំនាក់ទំនងនៅក្នុងក្រុមប្រឹក្សាឃុំ ..... ២៥

៦.៥ ថវិកាក្រុមប្រឹក្សាឃុំ សង្កាត់ ..... ២៧

៦.៦ ដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន ..... ២៨

៦.៧ ការផ្តល់សេវាកម្មសាធារណៈ ..... ២៩

៦.៨ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ............................................................................................. ៣២
៧. ការចូលរួមរបស់ប្រជាពលរដ្ឋ .......................................................................................... ៣៥
៨.បញ្ហាកើតឡើងថ្មីៗ.................................................................................................... ៣៨
៨.១ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក).................................. ៣៨
៨.២ ការផ្តោតលើការប្រែប្រួលអាកាសធាតុនៅថ្នាក់ឃុំ សង្កាត់........................................... ៣៩
៨.៣ ការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ............................................... ៤០
៨.៤ ការផ្តោតលើការផ្តល់សេវាសង្គមក្នុងអាណត្តិទីបីរបស់ឃុំ សង្កាត់ ................................. ៤០
៩. សន្និដ្ឋាន និងមេរៀន .................................................................................................. ៤១
ឧបសម្ព័ន្ធ កៈ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ............................................................ ៤៥
ឧបសម្ព័ន្ធ ខៈ ឯកសារយោង......................................................................................... ៤៨

# អំពីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| BoG | គណៈអភិបាល |
| C/S | ឃុំ/សង្កាត់ |
| C/SF | មូលនិធិឃុំ/សង្កាត់ |
| CCs | ក្រុមប្រឹក្សាឃុំ |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CIP | កម្មវិធីវិនិយោគឃុំ |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា |
| CP | រាជធានី និងខេត្ត |
| CPP | គណបក្សប្រជាជនកម្ពុជា |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| D/M | ស្រុក/ក្រុង |
| DFT | ក្រុមសម្របសម្រួលថ្នាក់ស្រុក |
| DMK | ស្រុក ក្រុង ខ័ណ្ឌ |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| FP | អ្នកទំនាក់ទំនងកណ្តាល |
| FUNCINPEC | គណបក្សហ៊្វុនស៊ិនប៉ិច |
| IP3 | ផែនការអភិវឌ្ឍន៍បីឆ្នាំដំបូង (ផអ៣) |
| LDF | មូលនិធិអភិវឌ្ឍន៍មូលដ្ឋាន |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoI | ក្រសួងមហាផ្ទៃ |
| NAA | អាជ្ញាធរសវនកម្មជាតិ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) |

| | |
|---|---|
| NCDD-S | លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ |
| NP-SNDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ |
| NRP | គណបក្សនរោត្តមរណប្ញទ្ធិ |
| OL | ច្បាប់អង្គការ |
| PSDD | គម្រោងគាំទ្រការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNIF | មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ |
| SRP | គណបក្ស សម រង្ស៊ី |
| TSO | មន្ត្រីគាំទ្របច្ចេកទេស (ខេត្ត) |
| UNCDF | មូលនិធិអភិវឌ្ឍន៍ទុនសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| VCS | ភូមិ ឃុំមានសុវត្ថិភាព |
| WCCC | គណៈកម្មាធិការពិគ្រោះយោបល់ ស្ត្រី និងកុមារ (គ.ព.ស.ក) |

# សេចក្តីថ្លែងអំណរគុណ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ធ្វើការដើម្បីលើកកម្ពស់ប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋ។ តួនាទីដ៏សំខាន់មួយរបស់ខុមហ្វ្រែល គឺស្វែងយល់ពីការអនុវត្តន៍ថ្មីៗនៃវិមជ្ឈការ ការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងការចូលរួមរបស់ប្រជាពលរដ្ឋ។

ក្នុងការលើកកម្ពស់ការអនុវត្តន៍វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន ខុមហ្វ្រែលបានធ្វើការសិក្សាវាយតម្លៃនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជាកាលពីអាណត្តិទីមួយឆ្នាំ (២០០២-២០០៧)។ ជាការសិក្សាបន្ទាប់មកទៀត ខុមហ្វ្រែលក៏បានសិក្សាវាយតម្លៃនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅអាណត្តិទីពីរឆ្នាំ(២០០៧-២០១២)បន្តទៀត។ ការវាយតម្លៃនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់ពីការវិវត្តន៍នៃការអនុវត្តន៍ថ្មីៗនៃកំណែទម្រង់វិមជ្ឈការ និងវាយតម្លៃការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយនិងការចូលរួមរបស់ប្រជាពលរដ្ឋ។

ក្នុងការសិក្សាវាយតម្លៃនេះ ខុមហ្វ្រែលសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះម្ចាស់ជំនួយដូចជា Oxfam Novib, Forum Syd, NPA (Norwegian People's Aid) និងសហភាពអឺរ៉ុប (EU)។

ខុមហ្វ្រែល ក៏សូមអរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ក្រុមការងារវាយតម្លៃ ដែលមានលោក គឹម ឈន អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ លោក ប្លង់ បឿត មន្ត្រីកម្មវិធីជាន់ខ្ពស់ផ្នែកបណ្តាញ និងវេទិកាសាធារណៈ ក្រោមការណែនាំរបស់លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល។

ខុមហ្វ្រែលសូមសំដែងការដឹងគុណចំពោះអ្នកស្រី ម៉ៅ ផល្លី អ្នកសម្របសម្រួលផ្នែករដ្ឋបាលនៃគណៈកម្មាធិការ ខុមហ្វ្រែលដែលបានជួយកែសម្រួលអក្ខរាវិរុទ្ធ និងឃ្លាប្រយោគនៃរបាយការណ៍វាយតម្លៃនេះ និងសូមថ្លែងអំណរគុណផងដែរចំពោះអ្នកស្រី រស់ បណ្ដេត និងកញ្ញា ហឹង សុភាព ទីប្រឹក្សាស្រាវជ្រាវដែលបានជួយផលិតរបាយការណ៍វាយតម្លៃនេះឡើង។

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាបានបោះជំហានគួរអោយកត់សម្គាល់ ក្នុងការអនុវត្តន៍កំណែទម្រង់វិមជ្ឈការ អស់រយៈពេលមួយទសវត្សរកន្លងផុតទៅហើយ។ តាមរបាយការណ៍របស់ Blunt and Turner ក្នុងឆ្នាំ២០០៥ បានបង្ហាញពីការព្រួយបារម្ភអំពីវិមជ្ឈការនៅកម្ពុជា ថាតើកំណែទម្រង់ពិតជាអាចបន្ស៊ីជាមួយនឹងបរិបទសង្គមជាក់ស្តែងរបស់ប្រទេសបានឬយ៉ាងណា ដោយយើងបានដឹងហើយថាស្ថាប័នរាជរដ្ឋាភិបាល តែងតែអនុវត្តការងារតាមរបៀបឋានានុក្រម និងការគ្រប់គ្រងបែបចៅហ្វាយនាយ-កូនចៅ។ វិមជ្ឈការនៅក្នុងប្រទេសកម្ពុជាមានគោលបំណងដើម្បីពង្រឹងប្រជាធិបតេយ្យ និងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដោយបានផ្តល់សិទ្ធិក្នុងការសម្រេចចិត្តសំខាន់ៗ នៅតាមថ្នាក់មូលដ្ឋានតាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ។

បើតាមការវាយតម្លៃនៅអាណត្តិទីមួយរបស់អង្គការខុមហ្វ្រែលពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៧ បានផ្តល់ការយល់ដឹងដំបូងពីស្ថានភាពនៃដំណើរការកំណែទម្រង់វិមជ្ឈការ។ របាយការណ៍នៃការសិក្សាថ្មីនេះ មានគោលបំណងដើម្បីវាយតម្លៃជាបន្តនៃការងារសម្រេចបានក្នុងការអនុវត្តន៍កំណែទម្រង់វិមជ្ឈការនាពេលបច្ចុប្បន្ននេះ និងដើម្បីវាយតម្លៃការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអាណត្តិទីពីរនៃវិមជ្ឈការពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១២។ ការសិក្សានេះនឹងបង្ហាញខុមហ្វ្រែលអំពីស្ថានភាពបច្ចុប្បន្ន និងការប្រឈមទាក់ទងទៅនឹងកំណែទម្រង់វិមជ្ឈការ និងគូសបញ្ជាក់មេរៀនសំខាន់ៗដែលអាចមានសារៈប្រយោជន៍សម្រាប់ខុមហ្វ្រែល ក្នុងការរចនា និងរៀបចំផែនការសកម្មភាពរបស់ខ្លួន ។

ការសិក្សានេះគឺធ្វើឡើងដោយផ្អែកទៅលើរបាយការណ៍ដែលមានស្រាប់ និងរបាយការណ៍ស្រាវជ្រាវបន្តបន្ទាប់របស់ខុមហ្វ្រែល និងរបាយការណ៍ផ្សេងៗទៀតដែលបានមកពីស្ថាប័ននានាដែលក្នុងនោះរួមមានទីភ្នាក់ងាររាជរដ្ឋាភិបាលដែលបានធ្វើការងារពាក់ព័ន្ធទៅនឹងវិមជ្ឈការ។ វិធីសាស្ត្រក្នុងការវិភាគទិន្នន័យគឺធ្វើឡើងតាមរយៈការទាញយកខ្លឹមសារ និងការវែកញែកសំខាន់ៗដែលបានមកពីការសិក្សាថ្មីៗ ព្រមទាំងការពន្យល់បកស្រាយអំពីការសម្រេចបានធៀបទៅនឹងសមិទ្ធិផលនៅអណត្តិទីមួយនៃវិមជ្ឈការ។

របាយការណ៍នេះត្រូវបានគេបែងចែកជា៩ផ្នែក ដែលក្នុងនោះផ្នែកទី២ បានផ្តល់នូវសេចក្តីសង្ខេបពីការរកឃើញសំខាន់ៗ និងផ្នែកទី៣ បានបង្ហាញពីប្រវត្តិនៃដំណើរការកំណែទម្រង់វិមជ្ឈការ។ ផ្នែកទី៤ ពណ៌នាអំពីជំហាននាពេលបច្ចុប្បន្ននៃកំណែទម្រង់វិមជ្ឈការ និងផ្នែកទី៥ វាយតំលៃទៅលើការអនុវត្តន៍កំណែទម្រង់ក្នុងការស្វែងរកបញ្ហាសំខាន់ៗ និងភាពប្រឈមដែលរារាំងដល់ដំណើរការកំណែទម្រង់។ ផ្នែកទី៦ ផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ និងផ្នែកទី៧ សង្កត់ធ្ងន់ទៅលើកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ ផ្នែកទី៨ គឺទាក់ ទងទៅនឹងការកំណត់រកបញ្ហាថ្មីៗដែលកើតឡើង និងផ្នែកចុងក្រោយដែលជាផ្នែកទី៩ សំយោគ និងផ្តល់នូវមេរៀនជាច្រើនសម្រាប់ការសិក្សាបន្ត ។

បើទោះបីជារបាយការណ៍នេះបានផ្តល់នូវព័ត៌មានដ៏មានសារៈសំខាន់ក៏ដោយ កង្វះខាតនៅតែមានពាក់ព័ន្ធនឹងវិធីសាស្រ្តដែលក្រុមស្រាវជ្រាវបានយកមកប្រើ និងការខ្វះការចុះប្រមូលព័ត៌មានដើម្បីបញ្ជាក់បន្ថែមលើព័ត៌មានដែលមានស្រាប់។ តែបើទោះជាយ៉ាងនេះក្តី ក្រុមសិក្សាសង្ឃឹមយ៉ាងម៉ុតមាំថា របាយការណ៍នេះពិតជាមានសារៈប្រយោជន៍ដល់ម្ចាស់ជំនួយ និងអង្គការនានាដែលធ្វើពាក់ព័ន្ធនឹងវិមជ្ឈការ និងការអភិវឌ្ឍន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះអាចធ្វើជា ឯកសារយោងសម្រាប់ការស្រាវជ្រាវនាពេលអនាគត និងសម្រាប់ការរៀបចំផែនការយុទ្ធសាស្រ្តទាក់ទងនឹងវិមជ្ឈការផងដែរ។

# ២. សេចក្តីសង្ខេប

បើប្រៀបធៀបនឹងអាណត្តិទីមួយ អាណត្តិទីពីរនៃវិមជ្ឈការ (ឆ្នាំ២០០៧ ដល់ឆ្នាំ២០១២) បង្ហាញពីការរីកចំរើនមួយចំនួនទាក់ទងទៅនឹងកំណែទម្រង់វិមជ្ឈការ។ ទោះជាយ៉ាងនេះក្តី ការសិក្សារកឃើញថា មិនមានការផ្លាស់ប្តូរច្រើនទេទៅលើវិមជ្ឈការនយោបាយ ពាក់ព័ន្ធនឹងការបែងចែកអំណាចនយោបាយ ការត្រួតពិនិត្យតាមដាន ព្រមទាំងគណនេយ្យភាពបែបប្រជាធិបតេយ្យរបស់មន្ត្រីជាប់ឆ្នោតថ្នាក់មូលដ្ឋាននៅអាណត្តិទីពីរនេះ។ មានការបង្កើតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិតាមរយៈការបោះឆ្នោតអសកលសម្រាប់ថ្នាក់ខេត្ត ក្រុង ស្រុក និងខណ្ឌនៅឆ្នាំ២០០៩។ ក៏ប៉ុន្តែប្រព័ន្ធបោះឆ្នោតដែលបានប្រើសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនោះ នៅមិនទាន់មានប្រជាធិបតេយ្យ និងមិនទាន់ឆ្លុះបញ្ចាំងពីគោលការណ៍នៃសិទ្ធិក្នុងការបោះឆ្នោតជាសកលនៅឡើយ ។

ជាមួយនឹងការសម្រេចបានតិចតួចនៅឃុំសង្កាត់ វិមជ្ឈការរដ្ឋបាលបានផ្តោតការយកចិត្តទុកដាក់ភាគច្រើននៅថ្នាក់ស្រុក និងក្រុង។ រាជរដ្ឋាភិបាលបានចាប់ផ្តើមការរៀបចំ "កិច្ចការផ្ទេរមុខងារ" ដើម្បីផ្ទេរមុខងារដែលបានជ្រើសរើសទៅថ្នាក់ក្រោម ពោលគឺថ្នាក់ស្រុក និងក្រុង ហើយឥឡូវនេះគឺស្ថិតនៅក្នុងដំណាក់ទីមួយសាកល្បងដោយក្រសួង៥ រួមមាន ក្រសួងសុខាភិបាល ក្រសួងអប់រំយុវជន និងកីឡា ក្រសួងកសិកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក។ វិមជ្ឈការហិរញ្ញវត្ថុមិនត្រូវបានគេអនុវត្តនៅឡើយ បើទោះជាគេសង្កេតឃើញមានការផ្ទេរហិរញ្ញវត្ថុកាន់តែច្រើនឡើងពីថវិការដ្ឋទៅមូលនិធិឃុំ សង្កាត់។ រាជរដ្ឋាភិបាលក៏បានធ្វើការប្រមែប្រមូលធនធានដែលបានមកពីដៃគូអភិវឌ្ឍន៍ជាចំណូលបន្ថែមទៅលើមូលនិធិឃុំ សង្កាត់ផងដែរ។ ការផ្តោតការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលទៅលើមូលនិធិស្រុក ក្រុង ក៏ត្រូវបានគេសង្កេតឃើញផងដែរ ដែលនេះជាជំហានឈាននាំទៅរកការអនុម័តអនុក្រិត្យលេខ ៣៦ ស្តីអំពីការបង្កើតមូលនិធិស្រុក ក្រុង ដែលចាប់អនុវត្តក្នុងឆ្នាំ២០១៣។

ការអនុវត្តន៍វិមជ្ឈការបានរួមចំណែកទៅរកគោលដៅដ៏ធំទូលាយនៃរបៀបវារៈកំណែទម្រង់ គឺដើម្បីជំរុញដល់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ការសិក្សាបានរកឃើញថា គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំចំពោះប្រជាពលរដ្ឋមានភាពល្អប្រសើរ និងដំណើរការរៀបចំផែនការ និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំក៏ត្រូវបានពង្រឹងកាន់តែច្រើន

ជាងមុន ដើម្បីឆ្ពោះទៅរកគោលការណ៍ប្រជាធិបតេយ្យ។ ក្រុមប្រឹក្សាឃុំមានភាពស្និទ្ធិស្នាលជាមួយប្រជាពលរដ្ឋ ហើយការព្រួយបារម្ភរបស់ពួកគាត់ភាគច្រើនគឺ ផ្តោតទៅលើតម្រូវការមូលដ្ឋាន ដែលនេះបានបង្ហាញថា គម្លាតរវាងរដ្ឋ និងប្រជាពលរដ្ឋត្រូវបានកាត់បន្ថយនៅក្នុងកម្រិតមួយ ដូចដែលបានរំពឹងទុកនៅក្នុងទ្រឹស្តី។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាឃុំបានរួមចំណែកជាច្រើនក្នុងការដោះស្រាយជម្លោះនៅមូលដ្ឋាន និងការធានាអោយមានសន្តិភាព និងសុវត្ថិភាព បើទោះបីជាលទ្ធភាពរបស់ខ្លួននៅមានកម្រិតសម្រាប់ការងារអភិបាលកិច្ចមូលដ្ឋានក៏ដោយ។ ដោយសារតែមូលនិធិឃុំសង្កាត់ នៅមានកម្រិតតិចតួចនៅឡើយ ដូចនេះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែពឹងផ្អែកលើថវិកាខាងក្រៅ ដែលបានមកពីគណបក្សនយោបាយ ឬសប្បុរសជន ហើយប្រការនេះបានបង្កើតអោយមានប្រភេទផ្សេងទៀតនៃគណនេយ្យភាព។ ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចបានសមិទ្ធផលនៅក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ពាក់ព័ន្ធលើការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវលំជនបទ បើទោះបី ជាការរួមចំណែករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅលើសេវាកម្មសង្គមនៅមានកម្រិតនៅឡើយក្តី។ បញ្ហាប្រឈមមួយចំនួនក៏ត្រូវបានគេរកឃើញ ដែលរួមមានឥទ្ធិពលខាងក្រៅទៅលើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ ដែលតម្រូវអោយមានការយកចិត្តទុកដាក់ និងភាពនៅមានកម្រិតនៃតួនាទី និងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចការគ្រប់គ្រងធនធានធម្មជាតិ ដែលរារាំងដល់ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ ។

ការចូលរួមរបស់ប្រជាពលរដ្ឋនៅតែមានកម្រិតនៅក្នុងអាណត្តិទីពីរ បើទោះបីជាប្រជាពលរដ្ឋហាក់ដូចជាមានការយល់ដឹងកាន់តែប្រសើរឡើង ស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមរបស់អង្គការនានា។ ការចូលរួមមានកម្រិតទាប គឺបណ្តាលមកពីកង្វះខាតចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋទៅលើកិច្ចការក្រុមប្រឹក្សាឃុំ កត្តាសេដ្ឋកិច្ច និងវប្បធម៌ ជំនាញសម្របសម្រួល និងកង្វះខាតព័ត៌មានអំពីការប្រជុំ ការលើកទឹកចិត្ត និងក្តីសង្ឃឹមនៅក្នុងការចូលរួមប្រជុំ។ ការចូលរួមហាក់បីដូចជាត្រូវបានរឹតបន្តឹង នៅក្នុងកម្រិតនៃកិច្ចប្រជុំណាដែលមានសេចក្តីសម្រេចចិត្ត។ ខណៈពេលដែលការចូលរួមនៅមានកម្រិតទាបនៅក្នុងកិច្ចប្រជុំផ្លូវការ ប្រជាពលរដ្ឋចូលចិត្តលើកឡើងតម្រូវការរបស់ពួកគាត់ទៅមេភូមិ ឬចាស់ទុំក្នុងភូមិ។ នៅក្នុងកំឡុងពេលដែលចាំបាច់មួយចំនួន គេក៏សង្កេតឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋមានកម្រិតខ្ពស់ផងដែរ។

បញ្ហាថ្មីៗ ត្រូវបានគេរកឃើញ ដែលក្នុងនោះរួមមានការបង្កើតទូទាំងប្រទេសនូវគណៈកម្មាធិការស្ត្រី និងកុមារ (គ.ក.ស.ក) ការដាក់បញ្ចូលនៅក្នុងកិច្ចពិភាក្សាពាក់ព័ន្ធនឹងបញ្ហាការប្រែ

ប្រែប្រួលអាកាសធាតុ នៅថ្នាក់ឃុំ ការបង្កើតឡើងនូវសមាគមពីរ មួយសម្រាប់ឃុំ/សង្កាត់ និងស្រុក/ខណ្ឌ ហើយមួយទៀតសម្រាប់ក្រុមប្រឹក្សាខេត្ត ព្រមទាំងការប្តេជ្ញាចិត្តថ្មីរបស់ក្រុមប្រឹក្សាឃុំ នៅក្នុងអាណត្តិទីបីដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើសេវាសង្គម។

# ៣. ប្រវត្តិនៃការបោះឆ្នោតឃុំ សង្កាត់ និងវិមជ្ឈការ

កំណែទម្រង់ថ្នាក់ឃុំ សង្កាត់មានដើមកំណើតមកពីកម្មវិធីសិលាដែលបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៩៦។ កម្មវិធីនេះ ចាប់ផ្តើមឡើងដំបូងមានលក្ខណៈជាក្របខ័ណ្ឌដើម្បីកៀងគរធនធានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធពីបណ្តាដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាលដើម្បីឲ្យស្រេបតាមតម្រូវការ នៅតាមមូលដ្ឋានក្នុងខេត្តគោលដៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំដដែលនេះ ដោយមានការគាំទ្រពីមូលនិធិអភិវឌ្ឍន៍ទុនសហប្រជាជាតិ (UNCDF) មូលនិធិអភិវឌ្ឍន៍មូលដ្ឋាន (LDF) ត្រូវបានលើកឡើងដើម្បីផ្តល់ការគាំទ្រដល់ឃុំ សង្កាត់ ដែលជាគោលដៅ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០០។ LDF បានផ្ទេរធនធាន និងអំណាចក្នុងការធ្វើសេចក្តីសម្រេចដល់ថ្នាក់ឃុំ សង្កាត់ដើម្បីឲ្យគេអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងជាអាទិភាពតាមរយៈការធ្វើផែនការ។ ការធ្វើផែនការនេះធ្វើឡើងដើម្បីទទួលបានថវិកាពីមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន។ កម្មវិធីនេះ តាក់តែងឡើងដើម្បីជាការសាកល្បងក្នុងការធ្វើផែនការវិមជ្ឈការ និងវិសហមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន ដែលបានត្រួសត្រាយផ្លូវក្នុងការបង្កើតឡើងនូវច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្នុងឆ្នាំ ២០០១ និងការបង្កើតឲ្យមាននូវមូលនិធិឃុំ សង្កាត់ក្នុងឆ្នាំ២០០២។ ជាលទ្ធផល ការបោះឆ្នោតថ្នាក់ឃុំ សង្កាត់លើកទីមួយបានលេចចេញជារូបរាងឡើងក្នុងឆ្នាំ២០០២ លើកទីពីរក្នុងឆ្នាំ២០០៧ និងលើកទីបីក្នុងឆ្នាំ២០១២។

ក្នុងខណៈដែលការធ្វើវិមជ្ឈការក្នុងឆ្នាំ២០០២ បានផ្តោតជាសំខាន់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលក៏បានចាប់ផ្តើមធ្វើការយកចិត្តទុកដាក់នៅថ្នាក់ស្រុក ខណ្ឌ ខេត្ត និងក្រុង តាមរយៈការអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងឆ្នាំ២០០៥។ ក្របខ័ណ្ឌនេះបានកំនត់នូវលក្ខណៈចម្បងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា រដ្ឋបាលឯកភាព ការបោះឆ្នោតក្រុមប្រឹក្សាដោយមិនផ្ទាល់ និងការតែងតាំងគណៈអភិបាលនៅថ្នាក់ស្រុក ខណ្ឌ ខេត្ត និងក្រុង។ ការធ្វើកំណែទម្រង់ មានគោលបំណងបង្កើតឲ្យមានប្រព័ន្ធអភិបាលកិច្ចថ្នាក់

ក្រោមជាតិមួយដែលដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍មូលដ្ឋាន និងការផ្តល់សេវាសាធារណៈទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍។

បន្ទាប់ពីអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលហៅកាត់ថា ច្បាប់អង្គការ ក្នុងឆ្នាំ២០០៨ មក ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌមិនផ្ទាល់មួយបានធ្វើឡើងក្នុងឆ្នាំ២០០៩។ វាជាការបោះឆ្នោតមិនផ្ទាល់ ដោយសារមានតែក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាអ្នកមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ខេត្ត ស្រុក ខណ្ឌ រីឯសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែលត្រូវជ្រើសរើស គឺឆ្លុះបញ្ចាំងពីសមាសភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ បើទោះបីកន្លងមក ការយកចិត្តទុកដាក់បានផ្តោតទៅលើកម្រិតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌក៏ដោយ ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែដើរតួនាទីសំខាន់ក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដោយហេតុនេះហើយ ទើបការសិក្សាយើងផ្តោតសំខាន់លើការអនុវត្តន៍របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ក្នុងអាណត្តិទីពីរឆ្នាំ(២០០៧-២០១២)។ ជាមួយគ្នានេះ ការសិក្សាក៏បានលើកយកនូវស្ថានភាពជាទូទៅរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌផងដែរ។

# ៤. ស្ថានភាពបច្ចុប្បន្ន

បន្ទាប់ពីបានអនុម័តច្បាប់អង្គការនៅខែ មិថុនា ឆ្នាំ២០០៨ និងការបោះឆ្នោតក្រុមប្រឹក្សាមិនផ្ទាល់នៅថ្នាក់ក្រោមជាតិនៅខែឧសភា ឆ្នាំ២០០៩ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ដែលមានរយៈពេលដប់ឆ្នាំ និងផែនការអភិវឌ្ឍន៍បីឆ្នាំដំបូង (ផអ៣) ត្រូវបានអនុម័តក្នុងឆ្នាំ២០១០។ NP-SNDD និង ផអ៣ មានគោលបំណងបង្កើតឲ្យមានស្ថាប័នថ្នាក់ក្រោមជាតិប្រកបដោយលក្ខណៈប្រជាធិបតេយ្យ មានគណនេយ្យភាព និងប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិសម្រាប់អត្ថប្រយោជន៍របស់ប្រជាជាតិកម្ពុជាទាំងមូល។

ផអ៣ ផ្តោតជាសំខាន់លើបីឆ្នាំដំបូង (ពីឆ្នាំ ២០១១ដល់ ២០១៣) នៅថ្នាក់ស្រុក ខណ្ឌ។ ផអ៣ កំពុងតែត្រូវបានគេធ្វើការពិនិត្យឡើងវិញពីវឌ្ឍនភាព ប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹង

លទ្ធផលដែលរំពឹងទុក ដើម្បីផ្តល់ជាអនុសាសន៍ក្នុងការតាក់តែង និងអនុវត្តនូវអ្វីដែលមិនទាន់បាន អនុវត្តក្នុងដំណាក់កាលរបស់ ផអ៣ ក៏ដូចជាផ្តល់អនុសាសន៍សម្រាប់ដំណាក់កាលបន្ទាប់ទៀត របស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដើរតួនាទីយ៉ាងសំខាន់ក្នុងនាមជាអ្នកគ្រប់គ្រងលើកម្មវិធីជារួម និងតាមរយៈលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (NCDD-S) មានការទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ និងធ្វើការសម្របសម្រួលលើកម្មវិធីនានា។ កម្មវិធីជាតិ (NP-SNDD) ត្រូវបានប្រគល់ឲ្យស្ថាប័នជាតិប្រាំមួយ រួមមាន NCDD-S ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់។

កំណែទម្រង់វិមជ្ឈការតាមវិស័យមានការរីកចម្រើន ដោយសារមានការយល់ព្រមឲ្យមានការប្រគល់មុខងារមួយចំនួន។ ក្នុងពេលជាមួយគ្នានេះដែរ គ.ជ.អ.ប ក៏បានស្នើចេញឲ្យមានអនុក្រឹត្យ និងសេចក្តីណែនាំស្តីពីការកំណត់មុខងារ។ បច្ចុប្បន្ននេះ ការកំណត់មុខងារបានធ្វើឡើងក្នុងក្រសួងចំនួនប្រាំរួមមាន ក្រសួងកសិកម្ម សុខាភិបាល ធនធានទឹក អភិវឌ្ឍន៍ជនបទ និងក្រសួងអប់រំយុវជន និងកីឡា។ តាមការគ្រោង គេរំពឹងថា ការកំណត់មុខងារនឹងអាចបញ្ចប់ចុងឆ្នាំ២០១២។ ជំហានបន្ទាប់ នឹងឈានដល់ការពិនិត្យឡើងវិញនូវមុខងារ មុនពេលមុខងារទាំងនោះត្រូវបានផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ថ្នាក់ស្រុក ក្រុង បានបង្កើតនូវការិយាល័យមួយឈ្មោះថា "ការិយាល័យផែនការ និងឃុំ សង្កាត់" ដើម្បីផ្តល់ជាជំនួយបច្ចេកទេសនានាតាមតម្រូវការជាក់ស្តែង និងធនធានដែលមាន។ ថ្នាក់ស្រុក ក្រុង ក៏បានអញ្ជើញតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួម ក្នុងកិច្ចប្រជុំរបស់ខ្លួនក្នុងពេលសមស្របណាមួយ (NCDD Forthcoming)។

# ៥. ការពិនិត្យមើលដំណើរការកំណែទម្រង់: បញ្ហាចម្បង និងប្រឈម

## ៥.១ វិមជ្ឈការនយោបាយ

មានការកើនឡើងចំនួនក្រុង ស្រុក ខណ្ឌ សង្កាត់ ឃុំ និងភូមិ បើប្រៀបធៀបទៅឆ្នាំ២០០៧ និងក្រោយឆ្នាំ២០០៧។ ស្រុក ក្រុង ខណ្ឌចំនួនប្រាំបួន ឃុំ សង្កាត់ ចំនួន១២ និងភូមិចំនួន ១៤៥ ត្រូវបានបង្កើតឡើងថ្មី (NCDD 2011)។ ស្របពេលគ្នានេះដែរ ចំនួនក្រុមប្រឹក្សាឃុំក៏បានកើនឡើងពីចំនួន ១១.២៦១នាក់នៃអាណត្តិទី១ ទៅដល់ចំនួន ១១.៣៥៣នាក់ ក្នុងអាណត្តិទីពីរ ក្នុងនោះ ៥០.៤៥% នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ជាក្រុមប្រឹក្សាថ្មីដែលមិនធ្លាប់ជាប់ឆ្នោតពីមុនមក។

វិមជ្ឈការនយោបាយដែលកំណត់ក្នុងការសិក្សានេះ សំដៅដល់ការបោះឆ្នោតនៅថ្នាក់មូលដ្ឋាន ការបែងចែកអំណាចនយោបាយ ការពិនិត្យលើអំណាចនយោបាយ និងគណនេយ្យភាព និងលក្ខណៈប្រជាធិបតេយ្យរបស់មន្ត្រីដែលជ្រើសឡើងដោយការបោះឆ្នោត។ ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១១.៣៥៣ បានជាប់ឆ្នោត ក្នុងនោះ មាន១.៨១២ រូបជាស្ត្រីដែលស្មើនឹង ១៦.១០%។ របាយការណ៍របស់ COMFREL ឆ្នាំ២០០៧ ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ បានទទួលស្គាល់នូវការរីកចម្រើន ផ្នែកនយោបាយក្នុងអណត្តិទីពីរ។ ក្នុងអណត្តិទីពីរនេះផងដែរ ក៏បានឆ្លុះបញ្ចាំងពីការកើនឡើងនូវចំនួនគណបក្សនយោបាយនៅអភិបាលកិច្ចថ្នាក់មូលដ្ឋាន។ ប្រហែល ៩០% នៃចំនួនឃុំ សង្កាត់ទាំង ១.៦២១ មានសមាជិកក្រុមប្រឹក្សាពីសំណាក់គណបក្ស ផ្សេងៗដូចជា÷

- គណបក្សប្រជាជនកម្ពុជាទទួលបាន៦១%នៃចំនួនសន្លឹកឆ្នោត ស្មើនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ ៧.៩៩៣រូប ឬស្មើនឹង ៧០% នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុប ។
- គណបក្ស សម រង្ស៊ី ទទួលបាន២៥% នៃចំនួនសន្លឹកឆ្នោត ស្មើនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ ២.៦៦០រូប ឬស្មើនឹង ២៣% នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុប។
- គណបក្សនរោត្តមរណឫទ្ធិ ទទួលបាន៨% នៃចំនួនសន្លឹកឆ្នោត ដែលចំនួនក្រុមប្រឹក្សាឃុំ សង្កាត់មាន ៤២៥រូប ឬស្មើនឹង៤.៥% នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុប។
- គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៥% នៃចំនួនសន្លឹកឆ្នោតសរុប ស្មើនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ ២៧៤រូប ឬស្មើនឹង ២.៥% នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុប។

ឃុំដែលមានគណបក្សសម រង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិចឈ្នះឆ្នោតជាមេឃុំ គឺភាគច្រើនស្ថិតនៅក្នុងតំបន់ដាច់ស្រយាល ដែលអាចឲ្យយើងដឹងពីតុល្យភាពនៃអំណាច (Check and Balance) រវាងគណបក្សនយោបាយដែលមិនកាន់អំណាច និងអាជ្ញាធរដែលមកពីគណបក្សប្រជាជនដូចជា ក្នុងការដោះស្រាយបញ្ហាដីធ្លី ឬបញ្ហាអភិបាលកិច្ច។ គណបក្សសម រង្ស៊ីមាននៅក្នុងឃុំរួមមាន ឃុំសូភី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ខេត្តរតនគីរី ឃុំឆែបពីរ ស្រុកឆែប និងឃុំភ្នំត្បែងពីរ ស្រុកគូលែន ខេត្តព្រះវិហារ និងឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ គណបក្សហ៊្វុនស៊ិនប៉ិចមាននៅក្នុងឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង និងឃុំអំពិល ស្រុកបន្ទាយអំពិល ក្នុងខេត្តឧត្តរមានជ័យ។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD ២០១០-២០១៩) បានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានាដើមឆ្នាំ២០១០។ ចាប់ផ្ដើមពីឆ្នាំ២០១០នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមអនុវត្ត NP-SNDD ដោយប្រគល់អំណាចច្រើនជាងមុនដល់ថ្នាក់មូលដ្ឋាន និងផ្ដល់អំណាចដល់ប្រជាពលរដ្ឋឲ្យចូលរួមចំណែកក្នុងប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។ បើទោះជាយ៉ាងនេះក្ដី ប្រព័ន្ធនៃការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ មិនបានឆ្លុះបញ្ចាំងពីគោលបំណងនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ដូចដែលបានចែងនៅក្នុងគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទេ។ ស្ថិតក្រោមប្រព័ន្ធបោះឆ្នោតសម្រាប់ថ្នាក់ក្រោមជាតិសព្វថ្ងៃ ប្រជាជនម្ចាស់ឆ្នោតមិនអាចពង្រឹងគណនេយ្យភាពរបស់មន្ត្រីដែលជាប់ឆ្នោតបានទេ។ ឆ្លងតាមការស្ទាបស្ទង់មតិរបស់ COMFREL និងតាមរយៈវេទិកាជាមួយប្រជាពលរដ្ឋ បានឲ្យដឹងថាប្រជាពលរដ្ឋមិនសូវមានជំនឿលើប្រព័ន្ធបោះឆ្នោតនេះទេ ហើយពួកគេស្នើឲ្យមានការបោះឆ្នោតដោយផ្ទាល់ ដើម្បីជ្រើសរើសថ្នាក់ដឹកនាំនៅថ្នាក់ខេត្ត ក្រុង ស្រុក និងខណ្ឌ។

គេរកឃើញថា គំនិតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅដើរតាមរបត់ឋានានុក្រមរដ្ឋបាលចាស់។ ឥរិយាបថ និងទម្លាប់ចាស់ៗ ក្នុងការគ្រប់គ្រងនៅតែបន្ត ការសម្រេចចិត្តទៅតាមក្រុម បក្សពួក និងបុគ្គល ជាជាងការធ្វើសម្រេចចិត្តដោយប្រជាពលរដ្ឋមូលដ្ឋាន។ បន្ថែមពីលើនេះ ការយល់ដឹងទាក់ទងនឹងតួនាទី និងការចូលរួមរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល នៅមានកម្រិតនៅឡើយ។

ក្នុងអំឡុងអាណត្តិទីពីរនេះ ក៏មានការលេចចេញឡើងនូវការបោះឆ្នោតមិនផ្ទាល់ ក្នុងការជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុកខណ្ឌ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩។ ការបោះឆ្នោតនេះ

គឺផ្អែកលើប្រព័ន្ធបោះឆ្នោតតាមបែបសមាមាត្រ ដែលតាមរយៈប្រព័ន្ធនេះគណបក្សនយោបាយត្រូវធ្វើការរៀបចំនូវបញ្ជីបេក្ខជនរបស់ខ្លួន ហើយអ្នកដែលអាចបោះឆ្នោតបានគឺជាក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រព័ន្ធនេះអនុញ្ញាតឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការបោះឆ្នោតឲ្យគណបក្សរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់បោះឆ្នោតឲ្យគណបក្សនយោបាយរបស់ខ្លួន ជាជាងបោះឆ្នោតឲ្យបេក្ខជនតាមការជ្រើសរើសរបស់ប្រជាពលរដ្ឋ ទាំងនៅក្នុងការបោះឆ្នោតព្រឹទ្ធសភា ឆ្នាំ២០០៦ និងការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០០៩។ ដូច្នេះហើយ ចំនួនកៅអីដែលទទួលបានគឺសមមាត្រទៅនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ដែលភាគច្រើនមកពីគណបក្សប្រជាជនកម្ពុជា (ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ស្មើនឹង៧.៩៩៣រូប) គណបក្សសម រង្ស៊ី (ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ ស្មើនឹង២.៦៦០រូប) គណបក្សនរោត្តមរណឫទ្ធិ (ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ ស្មើនឹង៤២៥រូប) និងគណបក្សហ្វ៊ុនស៊ិនប៉ិច (ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ ស្មើនឹង២៧៤រូប)។ គេអាចធ្វើការព្យាករណ៍ពីលទ្ធផលនៃការបោះឆ្នោតសម្រាប់ព្រឹទ្ធសភា និងថ្នាក់ក្រោមជាតិបានដោយងាយ។ លទ្ធផលនៃការបោះឆ្នោតមិនផ្ទាល់ ក្នុងការជ្រើសរើសក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០០៩ បានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបាន ២.៥៥១ កៅអី គណបក្សសម រង្ស៊ីទទួលបាន ៥៧៩កៅអី គណបក្សនរោត្តមរណឫទ្ធិទទួលបាន ៤៤កៅអី និងគណបក្សហ្វ៊ុនស៊ិនប៉ិចទទួលបាន ៦១ កៅអី។ ប្រព័ន្ធបោះឆ្នោតដោយមិនផ្ទាល់ដែលមានអ្នកបោះឆ្នោតមកពីគណបក្សធំៗ អាចឲ្យគេដឹងបានពីលទ្ធផល។ ប្រព័ន្ធនយោបាយនៅថ្នាក់មូលដ្ឋាន បង្ហាញថា មេឃុំ ចៅសង្កាត់ និងមេភូមិ មកពីគណបក្សប្រជាជនកម្ពុជាមានចំនួន ៩៨% ។

មានគណបក្សផ្សេងៗចំនួនប្រាំពីរជាតំណាងមកពីក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែមានតែគណបក្សបួនប៉ុណ្ណោះ ដែលទទួលបានចំនួនកៅអីច្រើនជាងគេក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងនោះ គណបក្សកាន់អំណាចទទួលបាន ៧៨% នៃចំនួនកៅអីសរុប។ មានតែ ៣៦៣កៅអីប៉ុណ្ណោះដែលបានទៅលើក្រុមប្រឹក្សាជាស្ត្រី ក្នុងចំណោមកៅអីសរុបចំនួន ២.៨៤០ ដែលស្មើនឹង ១៣%។ បច្ចុប្បន្ននេះ រចនាសម្ព័ន្ធនៅថ្នាក់ក្រុង ស្រុក ខណ្ឌ បានបង្កើតឡើងរួចរាល់ និងកំពុងដំណើរការ (NCDD Forthcoming)។

ការធ្វើឲ្យមានស្វ័យភាពនៅកម្រិតស្រុក ក្រុង និងថ្នាក់ក្រោមជាតិ គឺជាកត្តាចាំបាច់ដើម្បីធ្វើឲ្យសម្រេចបាននូវគោលបំណងរបស់ ជអ៣ (NCDD Forthcoming)។ ច្បាប់អង្គការបានចែងពីរចនាសម្ព័ន្ធរបស់ស្រុក ក្រុង និងរដ្ឋបាលថ្នាក់ក្រោមជាតិ រីឯស្វ័យភាពនេះត្រូវបានប្រគល់ទៅឲ្យ

ក្រុមប្រឹក្សាទាំងនោះ។ បើទោះជាយ៉ាងនេះក្តី វាមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងទាក់ទងទៅនឹងសមត្ថភាពក្នុងការទទួលបាននូវស្វ័យភាពក្នុងចំណោមក្រុមប្រឹក្សាក្រុង ស្រុក។ ក្រុមប្រឹក្សាស្រុក ក្រុងមួយចំនួនមានដំណើរការល្អទៅមុខ ដោយសារគេធ្វើការចុះសម្រុងបានល្អជាមួយគណៈអភិបាល។ ក្រុមប្រឹក្សាក្រុង ស្រុកផ្សេងទៀតនៅមិនទាន់យល់បានច្បាស់ពីមុខងារ តួនាទីរបស់ខ្លួនជាពិសេសសកម្មភាពដែលទាក់ទងនឹងការធ្វើផែនការ និងថវិកា ដែលធ្វើឲ្យពួកគេដើរតួតិចតួច និងពឹងផ្អែកយ៉ាងខ្លាំងលើគណៈអភិបាល។

នៅក្នុងអាណត្តិទីពីរ ឆ្លងតាមរយៈការលើកកម្ពស់ការយល់ដឹង បានបង្ហាញឲ្យឃើញពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការសម្រេចចិត្ត ការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន កម្មវិធីវិនិយោគនៅថ្នាក់ឃុំ សង្កាត់ដោយលើកឡើងពីបញ្ហា និងតម្រូវការជាអាទិភាព និងការរៀបចំអនុវត្តគម្រោង។ ផ្អែកលើការបណ្តុះបណ្តាលដែលផ្តល់ដោយក្រសួងមហាផ្ទៃ បានបង្ហាញថា ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលអាចជួយបង្កើននូវសមត្ថភាពក្នុងការអនុវត្តន៍តួនាទីរបស់ពួកគេ (NCDD 2011)។

## បញ្ហាប្រឈម[1]

- គណបក្សប្រជាជននៅតែដឹកនាំផ្តាច់មុខក្នុងឃុំចំនួន ១៦៦ និងបានកាន់កាប់ កៅអីទាំងអស់ដែលប្រៀបធៀបទៅឆ្នាំ ២០០២ មានចំនួនតែ១៤៨។ ក្នុងចំណោមមេឃុំចំនួន ១.៦២១ រូប មានតែមេឃុំ ២៨ រូបមកពីគណបក្ស សម រង្ស៊ី និង២ រូបមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច។ ក្តីបារម្ភចម្បងសម្រាប់គណបក្សផ្សេងទៀតដែលមិនមែនជាគណបក្សប្រជាជនកម្ពុជា នោះគឺពួកគេមានការពិបាកក្នុងការជ្រើសរើសបេក្ខជនឲ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ ស្ថានភាពនេះធ្វើឲ្យគណបក្សប្រជាជនកម្ពុជា គឺជាគណបក្សដែលចូលរួមប្រកួតប្រជែងតែមួយគត់ និងបេក្ខជនរបស់គណបក្សនេះ នឹងកាន់តែកើនឡើងក្នុងការបោះឆ្នោតនាពេលអនាគត។
- ប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ន មិនអនុញ្ញាតឲ្យប្រជាពលរដ្ឋធម្មតាឈរឈ្មោះបោះឆ្នោតបានទេ។ ប្រព័ន្ធបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិបច្ចុប្បន្ន គឺផ្អែកទៅ

[1] បញ្ហាប្រឈមនេះ គឺផ្អែកទៅលើរបាយការណ៍របស់ COMFREL ឆ្នាំ ២០០៧ស្តីពីការវាយតម្លៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ

លើបញ្ជីបេក្ខជនរបស់គណបក្ស ដែលជាហេតុធ្វើឲ្យក្រុមប្រឹក្សាមានការទទួលខុសត្រូវ និងស្មោះត្រង់ទៅកាន់ថ្នាក់ដឹកនាំបក្សរបស់ខ្លួន ជាជាងទៅកាន់អ្នកដែលបោះឆ្នោតឲ្យ។ បន្ថែមពីលើនេះ គណបក្សនយោបាយមានសិទ្ធិដកបេក្ខជនចេញពីបញ្ជី បើទោះបីបេក្ខជននោះត្រូវបានប្រជាជន បោះឆ្នោតហើយក៏ដោយ។

- ធនធានត្រូវចំណាយច្រើនលើការបណ្តុះបណ្តាលផ្នែកសមត្ថភាព ដោយសារតែវាត្រូវចាប់ផ្តើម និងធ្វើឡើងជាបន្តបន្ទាប់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ថ្មី (៩០.៩៥%)។ ដូច្នេះគេត្រូវការ ការបណ្តុះបណ្តាលលើផ្នែកសមត្ថភាពដើម្បីឲ្យពួកគេ អាចបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ។

## ៥.២ វិមជ្ឈការរដ្ឋបាល

ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីផ្សេងទៀតក្នុងនាមជាភ្នាក់ងារ ដូចបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ តួនាទីនេះរួមមានដូចជា ធ្វើសំបុត្រកំណើត ធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះបញ្ជីដីធ្លីជាដើម។ល។ ដោយមានការគាំទ្រទាំងផ្នែកសម្ភារៈ ថវិកា និងការអភិវឌ្ឍន៍ធនធានមនុស្ស (NCDD 2011)។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង NP-SNDD បានចែងពីការប្រគល់មុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ មិនទាន់មានការប្រគល់មុខងារណាមួយនៅឡើយ។ វាទាមទារឲ្យមានការសិក្សាដែលល្អិតល្អន់មួយ រួមជាមួយយុទ្ធសាស្ត្រ និងមុខងារច្បាស់លាស់ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងទៀត (NCDD 2011)។

នៅកម្រិតថ្នាក់ស្រុក ក្រុង ខណ្ឌ ក្រៅពីការដាក់ឲ្យមាននូវរចនាសម្ព័ន្ធ និងបង្កើតឲ្យមានស្វ័យភាពហើយ ចំនុចសំខាន់ផ្សេងទៀតក្នុងដំណាក់កាលដំបូងរបស់ NP-SNDD គឺការផ្ទេរមុខងារថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងធនធានមនុស្ស និងថវិកា ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (NCDD Forthcoming)។

ការធ្វើវិមជ្ឈការមុខងារជាក់លាក់មួយចំនួនពីថ្នាក់ជាតិ កំពុងតែត្រូវបានរៀបចំឡើង និងស្ថិតក្នុងដំណាក់កាលធ្វើការកំណត់មុខងារនៅក្នុងក្រសួងចំនួនប្រាំ (ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក)។ ការកំន

ត់ មុខងារនេះ រំពឹងថានឹងបញ្ចប់នាចុងឆ្នាំ២០១២ ប៉ុន្តែគេត្រូវចំណាយពេលយូរជាងនេះ។ ជំហានបន្ទាប់ គឺធ្វើការពិនិត្យមុខងារឡើងវិញ ដើម្បីឈានទៅដល់ការសម្រេចមួយដ៏ពិតប្រាកដក្នុងការផ្ទេរមុខងារពីថ្នាក់ជាតិ ទៅកាន់ថ្នាក់ក្រោមជាតិ។

បញ្ហាប្រឈម

- គេអាចសន្សំបានទាំងពេលវេលា និងធនធាន ប្រសិនបើដំណើរការនៃការកំណត់មុខងារធ្វើឡើង ដោយកំណត់មុខងារដែលពាក់ព័ន្ធឲ្យបានច្បាស់លាស់ និងសមស្របក្នុងការធ្វើវិមជ្ឈការ។ ការផ្តល់មុខងារអាចសាកល្បងធ្វើលើវិស័យណាមួយ ដើម្បីកំណត់ពីភាពជោគជ័យឲ្យបានឆាប់រហ័ស និងគួរផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាដែលមានមន្ត្រីអាចអនុវត្តបាន (NCDD Forthcoming)។

## ៥.៣ វិមជ្ឈការហិរញ្ញវត្ថុ

ឃុំ សង្កាត់កន្លងមក បានទទួលធនធានហិរញ្ញវត្ថុពីថវិកាឃុំ/សង្កាត់ ការចូលរួមរបស់ប្រជាពលរដ្ឋ និងតាមរយៈគម្រោងនិងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍។ ប្រភពចំនូលផ្ទាល់របស់ឃុំ សង្កាត់ ដែលរួមមានដូចជា ចំនូលដែលបានមកពីពន្ធ និងមិនមែនពន្ធ និងប្រភពចំណូលផ្សេងទៀតមិនទាន់ត្រូវបានសិក្សា និងពិចារណានៅឡើយ (NCDD 2011)។

ថវិកាឃុំ សង្កាត់ត្រូវបានបង្កើត និងបង្កើនឡើងជាបន្តបន្ទាប់។ នៅក្នុងអាណត្តិទីពីររបស់ឃុំ សង្កាត់ រដ្ឋាភិបាលបានសម្រេចផ្ទេរចំណូលចរន្តរបស់ខ្លួនទៅឲ្យថវិកាឃុំ សង្កាត់ដែលស្មើនឹង ២.៥៦% ក្នុងឆ្នាំ ២០០៧ ២.៧០% ក្នុងឆ្នាំ ២០០៨ ២.៧៥% ក្នុងឆ្នាំ ២០០៩ និង២.៨០% ក្នុងឆ្នាំ ២០១០ និង២០១១។ រដ្ឋាភិបាលក៏បានជួយកៀងគរធនធានពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាធនធានបន្ថែមដល់ឃុំ សង្កាត់គោលដៅ។ ឃុំ សង្កាត់ ទទួលផងដែរនូវថវិកាចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងមូលដ្ឋានពីឆ្នាំ ២០០៧ ដល់ ឆ្នាំ ២០១០ ក្នុងចំនួន ៥,៦៥៦,៦៩០.០០០ រៀល (ប្រហែល ១,៤១៤,១៧៣ ដុល្លារ សហរដ្ឋអាមេរិច)។

ឃុំ សង្កាត់បានចូលរួមអភិវឌ្ឍន៍មូលដ្ឋាន បើទោះបីមិនមានមុខងារច្បាស់លាស់ និងធនធានមានកម្រិតក៏ដោយ។ ឃុំ សង្កាត់បានចូលរួមក្នុងការផ្តល់សេវាសង្គម រួមមានដូចជា ការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការគ្រប់គ្រងធនធានធម្មជាតិ ការដោះស្រាយជម្លោះ ការ

គ្រប់គ្រងទីផ្សារ និងកាកសំណល់ (ជាពិសេសនៅទីប្រជុំជន) ការអប់រំ សុខភាព និងកសិកម្ម តាមរយៈការផ្តួចផ្តើមរបស់ក្រុមប្រឹក្សា ជាពិសេស មេឃុំ និងដើម្បីឆ្លើយតបទៅតាមតម្រូវការមូលដ្ឋាន។

តួនាទីឃុំ សង្កាត់ទាក់ទងមុខងារខាងលើនេះ មិនបានអនុវត្តដូចគ្នាទេ។ ក្រៅពីកត្តាភាពជាអ្នកដឹកនាំរបស់មេឃុំ ចៅសង្កាត់ មានកត្តាផ្សេងៗទៀតដូចជា ការគាំទ្រពីគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងកិច្ចសហការពីមន្ទីរជំនាញ។ ឃុំ សង្កាត់ មានបញ្ហាលំបាកក្នុងការបំពេញការងាររបស់ខ្លួន ដោយសារតែធនធានរបស់ខ្លួននៅមានកម្រិត។ ក្រុមប្រឹក្សាឃុំ សង្កាត់ស្នើសុំឲ្យមានការបង្កើត និងកំណត់ឲ្យបានច្បាស់លាស់ពីមុខងារដែលប្រគល់ឲ្យ និងធនធានអមជាមួយមុខងារនេះ។

តាំងពីឆ្នាំ២០០២ វិមជ្ឈការហិរញ្ញវត្ថុបានផ្តោតជាសំខាន់លើមូលនិធិឃុំ សង្កាត់។ វិមជ្ឈការហិរញ្ញវត្ថុនៅតែផ្តល់អាទិភាពដល់ឃុំ សង្កាត់ ប៉ុន្តែក៏ចាប់ផ្តើមផ្តល់ការយកចិត្តទុកដាក់នៅថ្នាក់ស្រុក និងក្រុងផងដែរ។ មុនពេលមានការបោះឆ្នោតមិនផ្ទាល់ឆ្នាំ ២០០៩ កំណែទម្រង់ថ្នាក់ខេត្ត និងស្រុកមានកម្រិតតិចតួច រីឯខេត្តចាត់ទុកដូចជាការពង្រីកពីថ្នាក់ជាតិប៉ុណ្ណោះ។ ខេត្តមានអំណាច និងធនធានតិចតួច ដែលធ្វើឲ្យគេមានលក្ខណៈដូចជាមន្ទីររបស់ក្រសួងមហាផ្ទៃ ចំណែកឯរដ្ឋបាលស្រុករឹតតែមិនអាចទទួល និងចាត់ចែងនូវធនធានបាន។

ធនធានហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការធ្វើឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានជាប់ឆ្នោតអាចបំពេញមុខងាររបស់ខ្លួនបាន ហេតុដូច្នេះហើយទើបគោលបំណងចម្បងទីពីររបស់ ផអព គឺធ្វើការផ្តល់ធនធានហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឲ្យគេអាចដំណើរការបាន។ ផអព បានធ្វើការបែងចែកនូវប្រភេទប្រភពចំណូលជាបួន សម្រាប់ក្រុម ស្រុក និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម÷

- មូលនិធិក្រុង ស្រុក (DMF)
- មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ
- មូលធនមានល័ក្ខខ័ណ្ឌតាមវិស័យ ផ្តល់ដល់មុខងារដែលបានផ្ទេរ និង
- ប្រភពចំណូលផ្ទាល់ខ្លួនដែលបានមកពីពន្ធ និងមិនមែនសារពើពន្ធ

អនុក្រឹត្យលេខ ៣៦ បានបង្កើតឲ្យមានមូលនិធិក្រុង ស្រុកតាមរយៈការផ្ទេរដោយគ្មានល័ក្ខខ័ណ្ឌពីថវិកាថ្នាក់ជាតិទៅក្រុង ស្រុក ដើម្បីបំពេញការងារទូទៅរបស់ខ្លួន ដូចជា ការចំណាយលើប្រាក់ខែ និងប្រាក់ឧបត្ថម្ភដល់ក្រុមប្រឹក្សា ចំណាយរដ្ឋបាល និងសម្រាប់ការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន។ ថវិកាក្រុង ស្រុក រំពឹងថានឹងចាប់ផ្តើមក្នុងឆ្នាំ ២០១៣ ចំណែកឯថវិកាផ្សេងទៀតមិនទាន់មាននៅឡើយ។

គួរកត់សម្គាល់ផងដែរថា ដោយមានការគាំទ្រពីធនាគារពិភពលោក និងថវិការដ្ឋ បច្ចុប្បន្ននេះ មានក្រុង ស្រុកចំនួន ១៧ បានសាកល្បងអនុវត្តកម្មវិធីច្រកចេញចូលតែមួយ។ ក្រុង ស្រុកដែលអនុវត្តកម្មវិធីនេះ ទទួលបាននូវបទពិសោធន៍ក្នុងការទទួលបានប្រាក់កម្រៃពេលផ្តល់សេវា ប៉ុន្តែភាគច្រើនមុខងារក្នុងការផ្តល់សេវានេះ គឺជាមុខងារដែលមន្ទីរជំនាញប្រគល់ឲ្យតែប៉ុណ្ណោះ និងមិនអនុញ្ញាតឲ្យក្រុង ស្រុកប្រើប្រាស់ចំណូលនោះឡើយ។ បន្ថែមពីលើនេះក្រុង ស្រុកអាចទទួលបាននូវចំណូលដែលបានមកពីការចូលរួមរបស់ប្រជាពលរដ្ឋ និងសប្បុរសជនក្នុងមូលដ្ឋាន (NCDD Forthcoming)។

# ៥.៤ ក្របខ័ណ្ឌច្បាប់ និងយន្តការគាំទ្រកំណែទម្រង់វិមជ្ឈការ

## ៥.៤.១ ក្របខ័ណ្ឌច្បាប់

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ គឺជាធាតុផ្សំដ៏ចាំបាច់បំផុតក្នុងដំណើរការកំណែទម្រង់ ដោយវាផ្តល់ជាវិធានសម្រាប់ដំណើរការគ្រប់កម្រិតនៃរដ្ឋបាល នយោបាយ និងហិរញ្ញវត្ថុ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រាជធានី ខេត្ត ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងដោយច្បាប់អង្គការ។ ដោយផ្អែកលើរដ្ឋធម្មនុញ្ញ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលទាក់ទងនឹងកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់សំខាន់ៗមួយចំនួនត្រូវបានអនុម័ត រួមមាន÷

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (២០០៨)
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (២០០៨)
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(២០០៨)
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ (២០១១)

ក្នុងចន្លោះឆ្នាំ ២០០៧ ដល់ ២០១១ មានលិខិតបទដ្ឋានគតិយុត្តិជាង ១៩២ ត្រូវបានបង្កើតឡើងដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឃុំ សង្កាត់ និងគោលនយោបាយមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងអំឡុងឆ្នាំ ២០១២ ឯកសារច្បាប់ និងគោលនយោបាយចំនួន ៩ បានបង្កើតឡើងផងដែរ រួមមាន អនុក្រឹត្យស្តីពី ដំណើរការទូទៅក្នុងការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ[2]។ ឯកសារសំខាន់ផ្សេងទៀតមានដូចជា អនុក្រឹត្យស្តីពីថវិកាក្រុង ស្រុក និង គោលការណ៍ណែនាំមួយចំនួន ទៀតទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុដែលរៀបចំដោយ NCDD-S ដោយមានការសហការជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត។

បើទោះបីជាច្បាប់ និងគោលនយោបាយមួយចំនួនត្រូវបានបង្កើតឡើង តែក៏នៅមិនគ្រប់គ្រាន់ រីឯតួនាទី និងមុខងាររបស់ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត ស្រុក ខណ្ឌ និងមន្ទីរជំនាញនៅមិនទាន់ច្បាស់លាស់ ដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការនៅឡើយ។ ដើម្បីដោះស្រាយបញ្ហាខាងលើ រដ្ឋាភិបាលបានដាក់ចេញជាកម្មវិធីជាតិដែលមានរយៈពេល ១០ ឆ្នាំ (កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ NP-SNDD) និងផែនការអភិវឌ្ឍន៍បីឆ្នាំដំបូង (ផអ៣) ដើម្បីធ្វើជាផែនទីដើម្បីដើរតាម។

**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ NP-SNDD (២០១០-២០១៩)**

NP-SNDD ចាត់ទុកជាឯកសារដ៏សំខាន់មួយបន្ថែមពីលើច្បាប់អង្គការ ក្នុងការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយវាផ្តល់នូវក្របខ័ណ្ឌសម្រាប់ការអនុវត្តន៍គម្រោង និងផែនការផ្សេងៗរបស់ គ.ជ.អ.ប និងលេខាធិការដ្ឋាន គ.ជ.អ.ប និងភាគីអនុវត្តផ្សេងទៀត សម្រាប់រយៈពេល ១០ឆ្នាំ។ ផ្អែកលើស្មារតីនៃច្បាប់អង្គការ ចំណុចផ្តោតរបស់ NP-SNDD គឺធ្វើការពង្រីកពីការកែទម្រង់នៅត្រឹមថ្នាក់ឃុំ សង្កាត់ ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតរួមមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (NCDD Forthcoming) ។

NP-SNDD នៅរក្សាគោលបំណងរយៈពេលវែងរបស់យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥ ដែលរួមមានប្រព័ន្ធគ្រប់គ្រងថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ដោយផ្អែកលើគោលការណ៍នៃ "ការចូលរួមតាមបែបប្រជាធិបតេយ្យ"។ បន្ថែមពីលើគោលបំណងដើម

[2] សូមមើលលម្អិតក្នុងឧបសម្ព័ន្ធ ក ស្តីពីក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

នេះ NP-SNDD បានធ្វើការបែងចែកការអនុវត្តន៍កំណែទម្រង់ជាបីដំណាក់កាល និងមានដាក់ជាគោលបំណងជាក់លាក់នៅក្នុងដំណាក់កាលនីមួយៗសម្រាប់រយៈពេល ១០ឆ្នាំ។

**ផែនការអភិវឌ្ឍន៍បីឆ្នាំដំបូង (ផអ៣)**

ផអ៣ បង្កើតឡើងដោយអនុលោមទៅតាមអ្វីដែលមានចែងក្នុង NP-SNDD (២០១០-២០១៩)។ ផអ៣ មានគោលបំណងបង្កើតឲ្យមានមុខងារ និងកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសគឺ ស្រុក ក្រុង ខណ្ឌ ឃុំ និងសង្កាត់ដើម្បីមានលទ្ធភាពបំពេញតួនាទីជាតំណាងរបស់ប្រជាពលរដ្ឋ និងឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋានរបស់ខ្លួន។

ផអ៣ បានផ្តោតជាសំខាន់លើ÷

- ការដាក់ស្រុក ក្រុងឲ្យនៅកៀកនឹងឃុំ សង្កាត់
- ផ្តោតទៅលើការសម្តែងមតិយោបល់ និងភាពជាតំណាង ដូចដែលបានចែងនៅក្នុងគោលបំណងកម្មវិធីរបស់ ផអ៣ ជាពិសេសបានបង្ហាញនូវបរិបទថ្មីស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យដែលលើសពីវិមជ្ឈការ និងវិសហមជ្ឈការ ។

**បញ្ហាប្រឈម**

- មានការខ្វះខាតឯកសារច្បាប់ និងគោលនយោបាយ ដោយភាគច្រើននៃឯកសារនោះនៅជាសេចក្តីព្រាងនៅឡើយ
- NCDD-S នៅមានកម្រិតក្នុងការសម្របសម្រួលឲ្យចេញនូវច្បាប់ និងគោលនយោបាយឲ្យបានគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការ
- រដ្ឋបាលថ្នាក់ក្រោមជាតិ ជួបការលំបាកក្នុងការយល់ដឹងឲ្យបានច្បាស់ពីអនុក្រឹត្យប្រកាសគោលនយោបាយ និងគោលការណ៍ណែនាំដែលមានច្រើនកន្លងមក

## ៥.៤.២ យន្តការគាំទ្រកំណែទម្រង់វិមជ្ឈការ

យន្តការគាំទ្រកំណែទម្រង់វិមជ្ឈការនៅទីនេះ សំដៅដល់តួអង្គសំខាន់ៗដែលដើរតួនាទីចម្បងក្នុងស្ថាប័ន ក្នុងការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលរួមមានដូចជា÷

ក្រសួងមហាផ្ទៃ៖ ក្រសួងមហាផ្ទៃនៅតែដើរតួនាទីដ៏សំខាន់ និងមានឥទ្ធិពល ក្នុងការរៀបចំឲ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥ និងជាអ្នកបង្កើតចេញនូវច្បាប់អង្គការឆ្នាំ២០០៨។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចូលរួមគាំទ្រជាបណ្តើរៗនៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយត្រូវគិតអំពីសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គ.ជ.អ.ប៖ ដូចដែលបានចែងក្នុងច្បាប់អង្គការ គ.ជ.អ.ប ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ក្នុងខែធ្នូ ឆ្នាំ២០០៨ និងមានតំណាងមកពីបណ្តាក្រសួងពាក់ព័ន្ធផ្សេងៗដែលមានតួនាទីក្នុងការធ្វើកំណែទម្រង់។ គ.ជ.អ.ប មានតួនាទីសម្របសម្រួល និងដឹកនាំការអនុវត្តន៍ច្បាប់អង្គការក្រោមការជួយពី លេខាធិការដ្ឋាន គ.ជ.អ.ប សម្រាប់ប្រតិបត្តិការការងារប្រចាំថ្ងៃ។

អាជ្ញាធរសវនកម្មជាតិ៖ អាជ្ញាធរសវនកម្មជាតិ ទទួលខុសត្រូវធ្វើសវនកម្មផ្ទៃក្រៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ អាជ្ញាធរនេះនៅមានបញ្ហាប្រឈមលើផ្នែកសមត្ថភាព ដែលមិនអាចឲ្យខ្លួនអាចបំពេញការងារទៅតាមតម្រូវការរបស់សវនកម្មបាន និងមានតួនាទីស្តួចស្តើងក្នុងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ៦. ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ

ក្របខ័ណ្ឌចំបងនៃការអនុវត្តន៍កំណែទម្រង់វិមជ្ឈការ គឺដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ក្នុងនាមជាស្ថាប័នប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតួនាទីកាត់បន្ថយគំលាតរវាងរដ្ឋ និងប្រជាពលរដ្ឋក្នុងទិសដៅលើកកំពស់ឱ្យប្រសើរឡើងលើការផ្តល់សេវាសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋ។ បច្ចុប្បន្នក្រុមប្រឹក្សាឃុំបានឈានមកដល់អាណត្តិទី៣ បន្ទាប់ពីមានការបោះឆ្នោតឃុំសង្កាត់នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២។ ដើម្បីស្វែងយល់ ថាតើរហូតមកដល់បច្ចុប្បន្នកំណែទម្រង់វិមជ្ឈការមានការវិវឌ្ឍន៍

កម្រិតណាក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គេត្រូវពិនិត្យមើលទៅលើការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំទាក់ទងនឹងចំណុចមួយចំនួនដូចខាងក្រោម។

## ៦.១ គណនេយ្យភាព

ការសិក្សារបស់ EIC (២០១០), Öjendal & Kim (២០១១), និង Plummer & Tritt (២០១១) បានរកឃើញដូចគ្នាថា ក្រុមប្រឹក្សាឃុំមានគណនេយ្យភាពទៅកាន់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំមានការយល់ដឹងកាន់តែប្រសើរឡើងអំពីកាតព្វកិច្ចរបស់ខ្លួន និងតម្រូវការរបស់ប្រជាពលរដ្ឋ ហើយចាត់ទុកតម្រូវការទាំងនោះជាអាទិភាពទីមួយរបស់ខ្លួន (Chheat, Lun et al. ២០១១)។ ដូចគ្នានេះដែរ ការសិក្សាស្ទង់មតិពីរផ្សេងគ្នាក៏បានបង្ហាញលទ្ធផលជាវិជ្ជមាន អំពីគណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំនៅក្នុងអាណត្តិទីពីរ។ EIC រកឃើញថាក្នុងឆ្នាំ២០១០ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំដែលបានសម្ភាសន៍ មាន៩៤% បានលើកឡើងថា ពួកគេមានគណនេយ្យភាពទៅកាន់ប្រជាពលរដ្ឋ។ ការសិក្សារបស់ CDRI ក្នុងឆ្នាំ២០១១ បានបង្ហាញថា ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំចំនួន៥៣១នាក់ ដែលបានសម្ភាស មាន៧០% បានអះអាងថាពួកគេមានគណនេយ្យភាពជាតំបូងចំពោះប្រជាពលរដ្ឋ (Chheat, Lun et al. ២០១១)។

ក្រុមប្រឹក្សាឃុំ មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាក់ទងនឹងការធ្វើសេចក្ដីសម្រេចចិត្ត (Öjendal and Kim ២០១១; Plummer and Tritt ២០១១) ។ សូម្បីបញ្ហាដែលមិនពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាឃុំក៏ព្យាយាមឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋផងដែរ (Kim and Öjendal ២០០៩; Plummer and Tritt ២០១១) ។ ក្រុមប្រឹក្សាឃុំជឿជាក់ថា កាតព្វកិច្ចរបស់ខ្លួនគឺត្រូវជួយដល់ប្រជាពលរដ្ឋដែលស្នើសុំជំនួយ (EIC 2010) ។ ក្រុមប្រឹក្សាឃុំខ្លួនឯងក៏បានបង្ហាញភាពយល់ស្របដែរថា ក្នុងនាមជាក្រុមប្រឹក្សាឃុំមិនត្រូវមានលក្ខណៈអត្តនោម័ត និងគាបសង្កត់ដល់ប្រជាពលរដ្ឋ ប៉ុន្តែត្រូវឆ្លើយតប និងផ្ដល់កិច្ចការពារ និងជំនួយគាំទ្រដល់ប្រជាពលរដ្ឋ (Kim and Öjendal ២០០៩) ។ បើទោះជាការសិក្សាស្ទង់មតិរបស់ EIC ២០១០ បានរកឃើញថា ជាងពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំដែលបានសម្ភាស នៅតែបង្ហាញភាពស្រពិចស្រពិលអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការពិនិត្យមើលឯកសាររបស់ឃុំក៏ដោយ ក៏ការសិក្សាដដែលនេះបានបង្ហាញថា មានសមាជិកក្រុមប្រឹក្សាឃុំ៩០% ទទួលស្គាល់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងការស្វែងយល់អំពីកិច្ចការរបស់ឃុំ ដោយរួមទាំងសិទ្ធិទទួលព័ត៌មានអំពីថវិកា។ ហេតុដូច្នេះពួកគេតែងតែផ្សព្វ

ផ្សាយការសម្រេចចិត្តរបស់ខ្លួនទៅកាន់ប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំភូមិ ឃុំ ឬតាមរយៈមេភូមិ។ ក្រុមប្រឹក្សាឃុំក៏បានធ្វើការផ្សព្វផ្សាយអំពីរបាយការណ៍វិវឌ្ឍន៍ និងការចាយវាយថវិកា តាមរយៈក្តារព័ត៌មានភូមិឃុំ (NCDD ២០១១) ។ ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំក្នុងការចែករំលែកព័ត៌មានទៅកាន់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងគោលការណ៍ គណនេយ្យភាពដែលមានចែងក្នុងទ្រឹស្តី។ យោងទៅតាម Schedler (១៩៩៩) គណនេយ្យភាពកើតឡើងនៅពេលបេក្ខជនជាប់ឆ្នោត ធ្វើការផ្សព្វផ្សាយព័ត៌មាន ឬពន្យល់ការសម្រេចចិត្តរបស់ខ្លួនទៅកាន់ប្រជាពលរដ្ឋ ផ្តោតការយកចិត្តទុកដាក់ទៅលើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលព័ត៌មាន និងចេញផ្សាយរាល់ព័ត៌មានពិស្តារចាំបាច់នានាដោយរួមទាំងព័ត៌មានច្បាស់ការណ៍ និងភស្តុតាង។

ខណៈដែលក្រុមប្រឹក្សាឃុំបានបង្ហាញអំពីគណនេយ្យភាពរបស់ខ្លួនទៅថ្នាក់ក្រោម ប្រជាពលរដ្ឋខ្លួនឯងក៏បានយល់ស្របថា ក្រុមប្រឹក្សាឃុំរបស់គេនៅក្នុងអាណត្តិទីពីរនេះមានការគោរពចំពោះប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតជាងនៅក្នុងអាណតិទីមួយ។ មាន៩៦%នៃអ្នកសម្ភាសន៍នៅឆ្នាំ២០០៩ (ដែលចំនួននេះកើនពី៨៧%នៅឆ្នាំ២០០៥) ជឿជាក់ថា ក្រុមប្រឹក្សាឃុំគោរពប្រជាពលរដ្ឋសាមញ្ញ (Öjendal and Kim ២០១១)។ នៅក្នុងការសិក្សាស្ទង់មតិមួយទៀតរបស់EIC ក្នុងឆ្នាំ២០១០បានបង្ហាញថា មាន៨៩%នៃប្រជាពលរដ្ឋដែលត្រូវបានសម្ភាស បានសំដែងមតិដូចគ្នាថាក្រុមប្រឹក្សាឃុំពិតជាបានចែករំលែកទិសដៅអាទិភាពរបស់ខ្លួនជាមួយប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋទាំងនោះ បានបង្ហាញភាពពេញចិត្តជាមួយនឹងការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំទៅលើចំណុចភាគច្រើននៃកិច្ចការអភិវឌ្ឍន៍ (EIC ២០១០) ។

គណនេយ្យភាពក៏សំដៅផងដែរទៅលើលទ្ធភាពនៃការអនុវត្តន៍ច្បាប់ មានន័យថា មន្ត្រីជាប់ឆ្នោត ត្រូវទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់ខ្លួន។ បើគ្មានការអនុវត្តន៍ច្បាប់ទេ គណនេយ្យភាពនឹងគ្មានប្រសិទ្ធិភាព (Schedler ១៩៩៩)។ ការអនុវត្តន៍ច្បាប់ត្រូវបានគេអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមទោះជាមិនទាន់គ្រប់គ្រាន់ក៏ដោយ។ Ann (២០០៨) បានរកឃើញថាប្រជាពលរដ្ឋនៅក្នុងឃុំសិក្សារបស់គាត់អាចឃ្លាំមើល និងពិនិត្យការអនុវត្តន៍របស់មន្ត្រីជាប់ឆ្នោតរបស់ខ្លួន ហើយប្រជាពលរដ្ឋទាំងនោះ អាចបោះឆ្នោតទំលាក់អ្នកដឹកនាំទាំងឡាយណាដែលបរាជ័យក្នុងការផ្តល់សេវាដែលខ្លួនបានសន្យា។ ដូចគ្នាដែរ ការសិក្សាស្ទង់មតិនៅឆ្នាំ២០០៩ បានរកឃើញថា ជាង៩០%នៃ៥៨៣នាក់ដែលត្រូវបានសម្ភាសន៍ បានអះអាងថា ពួកគេអាចធ្វើឲ្យក្រុមប្រឹក្សាឃុំមានគណនេយ្យភាពតាមរយៈការបោះឆ្នោតទំលាក់ ប្រសិនបើពួកគេមិនពេញចិត្តចំពោះការឆ្លើយតបរបស់ក្រុម

ប្រឹក្សាឃុំទាំងនោះ (Kim and Öjendal ២០០៩) ។ Plummer និង Tritt (២០១១) បានលើកយកឧទាហរណ៍ពីរដែលគួរឲ្យចាប់អារម្មណ៍មកបង្ហាញ។ ទីមួយគឺប្រជាពលរដ្ឋព្យាយាមបោះឆ្នោតទំលាក់ក្រុមប្រឹក្សាឃុំរបស់ខ្លួន ដែលបានបដិសេធមិនព្រមជួយគាំទ្រដល់ពាក្យបណ្ដឹងរបស់ពួកគេដែលប្ដឹងប្រឆាំងនឹងក្រុមហ៊ុនសម្បទានដីមួយកន្លែង និងឧទាហរណ៍មួយទៀតគឺ ប្រជាពលរដ្ឋបានតវ៉ា និងចុងក្រោយបានបណ្ដេញមេភូមិម្នាក់ឲ្យចេញពីតំណែងដោយសារពួកគេបានរកឃើញថាមេភូមិម្នាក់នោះមានកំហុសលើការគ្រប់គ្រងថវិកាវិភាគទានរបស់ប្រជាពលរដ្ឋ។

បន្ថែមពីនេះ ដើម្បីឲ្យក្រុមប្រឹក្សាឃុំមានគណនេយ្យភាព ប្រអប់គណនេយ្យភាពត្រូវបានគេប្រើប្រាស់។ ប្រអប់គណនេយ្យភាពចំនួន៣,០២៤ ត្រូវបានបំពាក់នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ/សង្កាត់ទូទាំងប្រទេស (NCDD ២០១១) ។ ពីឆ្នាំ២០០៧-២០១១ មានបណ្ដឹងចំនួន២.៣៧៩ ក្នុងនោះ៩៨៧(ប្រហែល៤២%) គឺពាក់ព័ន្ធនឹងបញ្ហាគណនេយ្យភាព។ ក្នុងចំណោម៩៨៧បណ្ដឹងនោះ មាន៤១៩ (ប្រហែល៤២%) ត្រូវបានដោះស្រាយដោយជោគជ័យ (NCDD ២០១១) ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅតែមិនច្បាស់ថា តើប្រអប់គណនេយ្យភាពអាចជួយលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំបានកម្រិតណា (NCDD ២០១២) ដែលចំណុចនេះទាមទារឲ្យមានការសិក្សាបន្ត។

## ៦.២ ដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត

ចាប់តាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំលើកទីមួយកន្លងមក ការសម្រេចចិត្តរបស់ឃុំសង្កាត់ត្រូវបានធ្វើឡើងទៅរកគោលការណ៍ប្រជាធិបតេយ្យ ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាឃុំ សង្កាត់។ ការធ្វើសេចក្ដីសម្រេចចិត្តរបស់ឃុំជាចំបង គឺពាក់ព័ន្ធនឹងការអនុវត្តន៍លើគំរោងផែនការវិនិយោគដើម្បីអភិវឌ្ឍន៍ប្រចាំឆ្នាំ និងការបែងចែកថវិកាឃុំ សង្កាត់។ Plummer & Tritt (២០១១) បានរកឃើញថា ការប្រើប្រាស់ថវិកាឃុំ សង្កាត់ត្រឹមកម្រិតណាមួយគឺផ្អែកទៅលើតម្រូវការ និងការចង់បានរបស់ប្រជាពលរដ្ឋ និងចំណេះដឹងមូលដ្ឋាន។ ការសម្រេចចិត្តនេះធ្វើឡើងផ្អែកទៅលើគោលការណ៍ច្បាប់ដើម្បីឲ្យមានតម្លាភាព (Plummer & Tritt ២០១១)។ វាចាប់ផ្ដើមពីក្រុមប្រឹក្សាឃុំពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពផែនការរបស់ខ្លួន និងដាក់ជូនដល់សិក្ខាសាលាសមាហរណកម្មស្រុក ដែលនៅទីនោះអ្នកពាក់ព័ន្ធនានា ដូចជាមន្ទីរជំនាញ និងអង្គការក្រៅរដ្ឋាភិបាលចូល

រួមឆ្លើយតបទៅនឹងអាទិភាពឃុំ។ បន្ទាប់ពីសិក្ខាសាលានេះបានបញ្ចប់ ក្រុមប្រឹក្សាឃុំត្រូវសម្រេចថា តើថវិកាឃុំគួរប្រើប្រាស់យ៉ាងដូចម្តេចក្នុងឆ្នាំនោះ។

ទោះជាយ៉ាងណាក៏ដោយ ការសម្រេចចិត្តនៅថ្នាក់ឃុំ នៅតែទទួលឥទ្ធិពលពីអ្នកពាក់ព័ន្ធខាងក្រៅ។ ការសម្រេចចិត្តរបស់ឃុំក្នុងការជ្រើសរើសអ្នកម៉ៅការសម្រាប់គំរោងអភិវឌ្ឍន៍ទទួលឥទ្ធិពលពីអាជ្ញាធរខេត្ត (ឧទាហរណ៍ មន្ត្រីគាំទ្របច្ចេកទេស និងក្រុមសម្របសម្រួលស្រុក )។ អាជ្ញាធរខេត្តមានតួនាទីជួយត្រួតពិនិត្យជាតំបូងលើសមត្ថភាពរបស់អ្នកម៉ៅការសម្រាប់ក្រុមប្រឹក្សាឃុំ។ ប៉ុន្តែអ្វីគួរឲ្យចាប់អារម្មណ៍នោះគឺថា អាជ្ញាធរខេត្តបានធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសពេលវេលា និងទីកន្លែងសម្រាប់រៀបចំកិច្ចប្រជុំដេញថ្លៃគំរោងដោយខ្លួនឯងតែម្តង។ ចំណុចនេះបានធ្វើឲ្យក្រុមប្រឹក្សាឃុំមានភាពភ័ន្តច្រឡំ ដោយសារខ្លួនហាក់ដូចជាបាត់សិទ្ធិអំណាចក្នុងការសម្រេចចិត្តចុងក្រោយលើការជ្រើសរើសអ្នកម៉ៅការ។ ការពន្យល់បញ្ជាក់ទៅលើការទទួលខុសត្រូវ និងការគ្រប់គ្រងរវាងក្រុមប្រឹក្សាឃុំ និងមន្ត្រីគាំទ្របច្ចេកទេស ពាក់ព័ន្ធបញ្ហាទាំងអស់នេះ គឺមានសារៈសំខាន់ដើម្បីធ្វើឲ្យក្រុមប្រឹក្សាឃុំមានភាពជាម្ចាស់កម្មសិទ្ធិឡើងវិញ និងម៉្យាងទៀតក្រុមប្រឹក្សាឃុំជាអ្នកទទួលខុសត្រូវកិច្ចការអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (Plummer & Tritt ២០១១) ។

ការតែងតាំងមេភូមិត្រូវបានផ្ទេរទៅឲ្យក្រុមប្រឹក្សាឃុំនៅឆ្នាំ២០០៦ ដើម្បីធានាឲ្យឃុំមានការគ្រប់គ្រងទៅលើធនធានមនុស្ស។ ទោះជាយ៉ាងនេះក្តី គេបានរកឃើញថាដំណើរការជ្រើសរើសមេភូមិមានពាក់ព័ន្ធនឹងបញ្ហានយោបាយ (Ann ២០០៨; Plummer and Tritt ២០១១) ។ ក្រុមប្រឹក្សាឃុំពីគណបក្សផ្សេងគ្នាព្យាយាមចរចារ និងប្រកួតប្រជែងដើម្បីទាមទារយកកន្លែងសម្រាប់បេក្ខជននៃគណបក្សរបស់ខ្លួន (Plummer and Tritt ២០១១)។

ក្រុមប្រឹក្សាឃុំក៏ដើរតួសំខាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចការផ្សេងៗ ដែលពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាល កម្មវិធីរបស់ក្រសួង ការផ្តល់ជំនួយ និងកិច្ចការពារធនធានធម្មជាតិនៅក្នុងឃុំរបស់ខ្លួន។ ខណៈដែលការសម្រេចចិត្ត ពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាល និងកម្មវិធីរបស់ក្រសួងពុំសូវមានភាពស្មុកស្មាញ តួនាទីរបស់ក្រុមប្រឹក្សាឃុំ ពាក់ព័ន្ធនឹងការផ្តល់ជំនួយពីខាងក្រៅបង្កប់នូវរឿងរ៉ាវមួយចំនួន។ មេឃុំនីមួយៗអាចកៀងគរធនធានពីខាងក្រៅ ជាពិសេសពីគណបក្សនយោបាយសម្រាប់ការវិនិយោគអភិវឌ្ឍន៍ឃុំរបស់ខ្លួន លុះត្រាតែពួកគាត់មានភាពសកម្មគ្រប់គ្រាន់ក្នុងបណ្តាញបក្សរបស់គាត់។ ពិតណាស់ថា ក្រុមប្រឹក្សាឃុំភាគច្រើនគឺសកម្មនៅក្នុងគណបក្ស

នយោបាយ តែទំនាក់ទំនងនិងបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗក៏បង្ហាញពីភាពសំខាន់ក្នុងការការកៀងគរជំនួយ និងការគាំទ្រពីខាងក្រៅផងដែរ (Thon, Ou et al. ២០០៩; Plummer and Tritt ២០១១) ។

ការសម្រេចចិត្ត និងតួនាទីរបស់ក្រុមប្រឹក្សាឃុំនៅក្នុងកិច្ចការពារធនធានធម្មជាតិ នៅតែមានកម្រិតនៅឡើយ។ (Heng, Kim et al. ២០១១) បានរកឃើញថា ជាទូទៅក្រុមប្រឹក្សាឃុំប្រឈមនឹងស្ថាប័នដែលមានអំណាចក្រៅផ្លូវការមួយចំនួន ដែលរារាំងដល់ការសម្រេចចិត្តក្នុងការការពារធនធានធម្មជាតិនៅក្នុងដែនរបស់ខ្លួន។ ស្ថាប័នទាំងនោះរួមមាន៖ (១) មន្ទីរនៅថ្នាក់ខេត្តដែលជាញឹកញាប់មានគណនេយ្យភាពទៅក្រសួងជំនាញ និងរំលងក្រុមប្រឹក្សាឃុំ (២) អ្នកមានអំណាចដែលតែងតែទទួលអាជ្ញាប័ណ្ណផ្ទាល់ពីថ្នាក់ជាតិពាក់ព័ន្ធនឹងធនធានធម្មជាតិ និង(៣) អាជ្ញាធរដែនដីមានអំណាចដូចជា យោធា ប៉ូលិស ឬមន្ត្រីថ្នាក់ខេត្តដែលតែងតែមានគណនេយ្យភាពទៅកាន់គណបក្សនយោបាយជាងទៅប្រជាពលរដ្ឋ។

## ៦.៣ ការដោះស្រាយជម្លោះ និងបញ្ហា

ខុមហ្វ្រែលក្នុងរបាយការណ៍វាយតម្លៃរបស់ខ្លួនឆ្នាំ២០០៧ បានរកឃើញថា បញ្ហាក្មេងទំនើង អំពើហិង្សាក្នុងគ្រួសារ និងជម្លោះដីធ្លី គឺជាបញ្ហាសំខាន់ដែលកើតមានឡើងនៅមូលដ្ឋាន។ ដោយឡែកអាណត្តិទីពីររបស់ក្រុមប្រឹក្សាឃុំ បង្ហាញថា ឃុំមិនត្រឹមតែជួបបញ្ហាដូចដែលបានរៀបរាប់ខាងលើនោះទេ មានបញ្ហាផ្សេងទៀតដែលឃុំបានជួបប្រទះដូចជាបញ្ហាថ្នាំញៀន និងករណីរំលោភសេពសន្ថវៈ។ ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា ក្នុងកំឡុងពេលពី៣ ទៅ៥ឆ្នាំកន្លងមកនេះ បញ្ហាលួចប្លន់ត្រូវបានគេរាយការណ៍ថាបានធ្លាក់ចុះ ហើយប្រជាពលរដ្ឋយល់ថាឆ្នាំ២០១០ មានអារម្មណ៍សុវត្ថិភាពក្នុងផ្ទះ និងនៅពេលយប់ល្អប្រសើរជាងឆ្នាំ២០០៧ (TAF 2011) ។

ការបោះឆ្នោតក្រុមប្រឹក្សាឃុំអាណត្តិទីពីរ ក៏បង្ហាញផងដែរនូវកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សានៅមូលដ្ឋាន តាមរយៈការអនុវត្តន៍គោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលបានអនុម័តនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។ បើយោងទៅតាមគោលនយោបាយនេះ ឃុំ ឬភូមិអាចចាត់ទុកថា មានសុវត្ថិភាពលុះត្រាតែភូមិឃុំនោះមិនមានការលួចប្លន់ ការផលិត ការចែកចាយ ឬការប្រើប្រាស់គ្រឿងញៀន ការរំលោភ ជួញដូរស្ត្រី និងកុមារ

ព្រមទាំងអំពើហឹង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង និងគ្មានការលេងល្បែងស៊ីសង ឬការប្រើប្រាស់អាវុធជាតិផ្ទុះខុសច្បាប់ និងបទឧក្រិដ្ឋ។

មេភូមិ និងក្រុមប្រឹក្សាឃុំមានតួនាទីសំខាន់ក្នុងការដោះស្រាយជម្លោះ និងបញ្ហានានា។ Öjendal & Kim (២០១១) បានរកឃើញថា មានប្រជាពលរដ្ឋដែលត្រូវបានគេសម្ភាសន៍ប្រមាណ ៨១% (កើនពី៥៥% ក្នុងឆ្នាំ២០០៥) បាននិយាយថា ក្រុមប្រឹក្សាឃុំជាទូទៅអាចដោះស្រាយជម្លោះនៅក្នុងភូមិ និងមាន៩១%និយាយថា ក្រុមប្រឹក្សាឃុំយកចិត្តទុកដាក់លើពាក្យបណ្ដឹងទាំងឡាយរបស់ពួកគេ ដូច្នេះពួកគេនឹងទៅសុំជំនួយពីក្រុមប្រឹក្សាឃុំទៀត ប្រសិនបើពួកគេមានបញ្ហានៅថ្ងៃក្រោយ។ លទ្ធផលនៃការផ្ដល់ពិន្ទុដែលរៀបចំដោយអង្គការខុមហ្វ្រែលក៏បានរកឃើញថា មានប្រជាពលរដ្ឋ៩៥% នៃ៨៣នាក់ ដែលអញ្ជើញមកពីឃុំដាច់ស្រយាល និងឃុំជនជាតិភាគតិចចំនួន៧ឃុំបានវាយតម្លៃថា ក្រុមប្រឹក្សាឃុំរបស់គេបានពង្រឹងទៅលើការអនុវត្តន៍គោលនយោបាយភូមិឃុំមានសុវត្ថិភាព (COMFREL ២០១៣)។ ចំណុចល្អរបស់មេភូមិ និងមេឃុំរួមមាន៖ ប្រជាពលរដ្ឋអាចទៅទំនាក់ទំនង ហើយពួកគាត់តែងតែជួយនៅពេលប្រជាពលរដ្ឋស្នើសុំ ពួកគាត់ចែកចាយព័ត៌មាន និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងពួកគាត់មានភាពយុត្តិធម៌ក្នុងការដោះស្រាយជម្លោះ (TAF ២០១១) ។

ពាក់ព័ន្ធនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរ ប្រជាពលរដ្ឋរាយការណ៍ទៅប៉ូលិស។ មូលហេតុដែលជម្រុញឲ្យប្រជាពលរដ្ឋរង់ចាំរហូតដល់មានបទឧក្រិដ្ឋធ្ងន់ធ្ងរទើបរាយការណ៍ទៅប៉ូលិស គឺដោយសារប៉ូលិសមួយចំនួនតែងតែទាមទារសុំប្រាក់ក្រៅផ្លូវការនៅពេលចុះអន្តរាគមន៍ (TAF ២០១១)។ របាយការណ៍វាយតម្លៃរបស់ខុមហ្វ្រែល២០០៧ ក៏បង្ហាញផងដែរអំពីការកើតឡើងនូវអំពើពុករលួយ និងបក្សពួកនិយមនៅក្នុងកិច្ចការផ្សះផ្សា ដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំនៅក្នុងអាណត្តិទីមួយ។ ក្នុងអាណត្តិទីពីរ (Thon, Ou et al. ២០០៩) បានរកឃើញថាក្រុមប្រឹក្សាឃុំក៏មានទទួលយកថវិកាជាសុគុណសម្រាប់ការជួយដោះស្រាយជម្លោះថ្នាក់មូលដ្ឋាន និងក្នុងការចេញសំបុត្រផ្សេងៗ។ ប៉ុន្តែលុយទាំងនោះពុំត្រូវបានក្រុមប្រឹក្សាឃុំចាត់ទុកថា ជាអំពើពុករលួយនោះទេ តែជាអំណោយ ឬកម្រៃដែលពួកគាត់ខិតខំផ្ដល់នូវសេវាជូនប្រជាពលរដ្ឋ។ ស្មៀនក៏ពាក់ព័ន្ធផងដែរទាក់ទងនឹងការទារកម្រៃលើសកំណត់សម្រាប់ការចុះឈ្មោះប្រជាពលរដ្ឋ (TAF ២០១១) ។

កំណើនសេដ្ឋកិច្ចបានធ្វើឲ្យតម្លៃដីធ្លីកើនឡើង និងការករកើតតំបន់សម្បទានដីសេដ្ឋកិច្ចជាច្រើនកន្លែងនៅក្នុងប្រទេសកម្ពុជា។ តួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងបរិបថនេះក៏មានភាពសកម្ម មិនត្រូវតែនៅក្នុងការចេញលិខិតទទួលស្គាល់ដីធ្លីប៉ុណ្ណោះទេ ថែមទាំងការជួយដោះស្រាយជម្លោះដីធ្លីថែមទៀត។ ក្នុងអាណត្តិទីពីរ បានបង្ហាញពីការកើនឡើងនូវជម្លោះដីធ្លីរវាងប្រជាពលរដ្ឋគ្នាឯង រវាងប្រជាពលរដ្ឋនិងក្រុមហ៊ុនសម្បទាន ឬអ្នកខាងក្រៅ ឬពេលខ្លះពាក់ព័ន្ធនឹងក្រុមប្រឹក្សាឃុំតែម្តង (Thon, Ou et al. ២០០៩) ។ ក្រុមប្រឹក្សាឃុំអាចដោះស្រាយជម្លោះដីធ្លីតូចៗបានយ៉ាងមានប្រសិទ្ធភាព ដោយប្រើយុទ្ធសាស្រ្តសម្របសម្រួល។ ប៉ុន្តែក្នុងជម្លោះធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងអ្នកមានអំណាចពីខាងក្រៅ នៅពេលដែលខ្លួនពុំអាចប្រឆាំងអ្នកមានអំណាចទាំងនោះបាន ក្រុមប្រឹក្សាឃុំបានអនុវត្តវិធីគាំទ្រសកម្មដោយមិនប្រឆាំងតបតភ្លាមៗ ប៉ុន្តែខិតខំសំណើរកជំនួយពីអាជ្ញាធរថ្នាក់លើឲ្យជួយអន្តរាគមន៍ (Plummer and Tritt ២០១១) ។ ដោយសារតែគ្មានអន្តរាគមន៍ផ្ទាល់ លើបញ្ហានេះហើយ ប្រជាពលរដ្ឋមួយចំនួនពុំបានចាត់ទុកថា ក្រុមប្រឹក្សាឃុំបានជួយដោះស្រាយជម្លោះដីធ្លីឡើយ។ ឧទាហរណ៍ យោងទៅលើរបាយការណ៍របស់ខុមហ្រ្វែល ២០១៣ បានឲ្យដឹងថា មានប្រជាពលរដ្ឋ៥៨%នៃ២០៧នាក់ ដែលបានចូលរួមធ្វើការផ្តល់ពិន្ទុដល់ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំបានសំដែងភាពមិនយល់ស្របដែរថា ក្រុមប្រឹក្សាឃុំបានជួយដោះស្រាយ ឬផ្សះផ្សាជម្លោះដីធ្លី (សម្បទានដីធ្លី) និងបានផ្តល់ដីព្រៃទៅឲ្យសហគមន៍ (COMFREL ២០១៣) ។

## ៦.៤ ទំនាក់ទំនងនៅក្នុងក្រុមប្រឹក្សាឃុំ

ការបោះឆ្នោតឃុំក្នុងឆ្នាំ២០០២ ២០០៧ និង២០១២ បានបង្កើតឲ្យមានប្រព័ន្ធគណបក្សនយោបាយពហុបក្ស នៅក្នុងរដ្ឋបាលថ្នាក់ក្រោមនៅកម្ពុជា។ ការរៀបចំនេះមានន័យថា រូបភាពនយោបាយនៅថ្នាក់មូលដ្ឋាន នៅកម្ពុជាមិនមែនគ្រប់គ្រងដោយគណបក្សតែមួយដូចពីមុននោះទេ (Ann ២០០៨) ។ ទោះជាយ៉ាងនេះក្តី តើប្រព័ន្ធគណបក្សនយោបាយពហុបក្សនៅថ្នាក់ឃុំនេះអាចបង្កើតកិច្ចពិភាក្សានយោបាយ និងជម្រើសប្រសើរជាងមុនសម្រាប់ប្រជាពលរដ្ឋកកម្រិតណា តម្រូវឲ្យមានការអង្កេតទៅលើកម្រិតទំនាក់ទំនងនៅក្នុងក្រុមប្រឹក្សាឃុំ។

ខុមហ្រ្វែល ២០០៧ បានរាយការណ៍អំពីការរើសអើង និងការប្រជែងគ្នារវាងសមាជិកក្រុមប្រឹក្សាពីសំណាក់គណបក្សផ្សេងគ្នានៅអាណត្តិទីមួយ។ ដោយឡែកនៅក្នុងអាណត្តិទីពីរ ការសិក្សាស្ទង់មតិជាច្រើន បានរកឃើញពីកិច្ចសហការរវាងសមាជិកក្រុមប្រឹក្សាឃុំក្នុងការឆ្លើយតប

នឹងតម្រូវការមូលដ្ឋានអាទិភាពរបស់ខ្លួន បើទោះជាការប្រកួតប្រជែងរវាងគណបក្សនយោបាយនៅតែកើតមានក៏ដោយ។ ក្នុងឃុំដែលគណបក្សប្រជាជនទទួលបានសម្លេងគាំទ្រច្រើន ការសម្រេចចិត្តលើកិច្ចការសំខាន់ៗហាក់ដូចជាទទួលរងឥទ្ធិពលពីគណបក្សនោះ ជាពិសេសទាក់ទងនឹងការបោះឆ្នោតជ្រើសរើសមេភូមិ។ គោលការណ៍ពីក្រសួងមហាផ្ទៃក្នុងឆ្នាំ២០០៦ បានកំណត់ថា មេភូមិនឹងត្រូវបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាឃុំ ហើយមេភូមិដែលជាប់ឆ្នោតនោះនឹងត្រូវអនុញ្ញាតឲ្យធ្វើការជ្រើសរើសអនុភូមិម្នាក់ និងជំនួយការម្នាក់ដោយខ្លួនឯង។ ដោយមើលឃើញសក្តានុពលរបស់មេភូមិក្នុងការកៀងគរសន្លឹកឆ្នោត គណបក្សប្រជាជនបានក្តាប និងពង្រីកបណ្តាញគណបក្សរបស់ខ្លួនចុះដល់ថ្នាក់ភូមិ។ ជាលទ្ធផល រចនាសម្ព័ន្ធភូមិនៅតែឋិតនៅក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាជនដដែល (Ann ២០០៨) ។

មានវិធីសាស្រ្តជាច្រើនត្រូវបានសមាជិកក្រុមប្រឹក្សាជាគណបក្សប្រជាជនប្រើប្រាស់ដើម្បីកៀងគរសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតមេភូមិឲ្យទៅបេក្ខជននៃគណបក្សរបស់គេ ក្នុងរូបភាពបែបប្រជាធិបតេយ្យ។ ទាំងនោះរួមមានការបង្កើតសម្ព័ន្ធភាពជាមួយគណបក្សនយោបាយដទៃសម្រាប់ដំណើរការបោះឆ្នោត និងការរៀបចំជាថ្នូរផ្សេងៗ។ (Ann ២០០៨) បានរកឃើញពីកង្វល់របស់ក្រុមប្រឹក្សានៃគណបក្សប្រឆាំង ដែលបានបង្ហាញពីចំណុចគុណវិបត្តិរបស់ខ្លួនដែលពុំអាចមានលទ្ធភាពកៀងគរសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតមេភូមិបាន។

បើទោះជាមានការប្រកួតប្រជែងរវាងគណបក្សនយោបាយក្តី ទិសដៅក្នុងការថែរក្សាតុល្យភាព អំណាច និងបន្ធូរបន្ថយភាពតានតឹងផ្នែកនយោបាយក៏ត្រូវបានគេរកឃើញថាផងដែរ (Plummer and Tritt ២០១១) ។ Plummer and Tritt (២០១១) បានបង្ហាញថា នៅឃុំដែលគណបក្សប្រឆាំងទទួលបានសម្លេងគាំទ្រច្រើន មេឃុំដែលជាគណបក្សប្រឆាំងនោះ ពុំសូវជ្រើសរើសបេក្ខជនតែពីគណបក្សខ្លួនដើម្បីធ្វើមេភូមិនោះទេ។ ការធ្វើបែបនេះគឺដើម្បីបន្ធូរបន្ថយភាពតានតឹងផ្នែកនយោបាយ និងចំណុចរសើបរបស់គណបក្សប្រជាជនដែលនៅថ្នាក់លើ។ ការធ្វើបែបនេះគឺដើម្បីបង្កឲ្យមានបរិយាកាសងាយស្រួលសម្រាប់កិច្ចការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ និងធានាឲ្យមានការគាំទ្រជាហូរហែពីថ្នាក់ដឹកនាំខាងលើ។

យ៉ាងនេះក្តី គណបក្សនយោបាយនីមួយៗនៅតែមានចន្លោះទំនេរដែលខ្លួនអាចសម្តែងភាពស្របច្បាប់របស់ខ្លួនបាន។ Ann (២០០៨) បានរកឃើញថា ខណៈដែលមេឃុំ (នៅឃុំសិក្សារបស់

គាត់) បានកំណត់យកយុទ្ធសាស្ត្រនៃការចែកអំណោយ ការសន្យា និងការគ្រប់គ្រងមេភូមិដើម្បីបង្កើនប្រជាប្រិយភាពរបស់ខ្លួនសម្រាប់ការបោះឆ្នោតអាណត្តិក្រោយ ជំទប់ទីមួយនៃឃុំដដែលនោះដែលមកពីគណបក្សប្រឆាំង បានប្រើយុទ្ធសាស្ត្រផ្សេងទៅវិញ ដោយគាត់ផ្អែកលើគុណធម៌ក្នុងការរក្សានូវភាពយុត្តិធម៌ និងមិនប្រព្រឹត្តិអំពើពុករលួយដើម្បីកសាងទំនុកចិត្តជាមួយប្រជាពលរដ្ឋ។ ដូចគ្នាដែរ នៅឃុំសិក្សាដទៃទៀតបានបង្ហាញថា ខណៈដែលក្រុមប្រឹក្សាឃុំមួយចំនួនព្រងើយកន្តើយលើបញ្ហាជម្លោះដីធ្លី មានសមាជិកក្រុមប្រឹក្សាមួយចំនួនផ្សេងទៀតបានបង្ហាញនូវការគាំទ្រដល់ប្រជាពលរដ្ឋ (Plummer and Tritt ២០១១) ។ សរុបជារួមមក ប្រការដែលក្រុមប្រឹក្សាឃុំមានចន្លោះផ្នែកនយោបាយ គឺជាចំនុចល្អព្រោះវាផ្តល់ជម្រើសប្រសើរជាងមុនទៅឲ្យប្រជាពលរដ្ឋ និងអាចធ្វើឲ្យគណបក្សនយោបាយនីមួយៗប្រកួតប្រជែងគ្នាសម្រាប់ប្រជាប្រិយភាពរបស់ខ្លួន។

## ៦.៥ ថវិកាក្រុមប្រឹក្សាឃុំ/សង្កាត់

ថវិកាក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលផ្ទេរពីរដ្ឋាភិបាលរួមមានប្រាក់ចំណូលពីពន្ធដារ និងការផ្តល់វិភាគទានពីសំណាក់ដៃគូអភិវឌ្ឍដើម្បីទ្រទ្រង់កិច្ចការរដ្ឋបាល និងកិច្ចអភិវឌ្ឍនៅមូលដ្ឋាន។ បន្ថែមពីនេះ ក្រុមប្រឹក្សាឃុំក៏មានតួនាទីក្នុងការប្រមូលធនធាននៅថ្នាក់មូលដ្ឋានរបស់ខ្លួន ប៉ុន្តែដោយសារ ក្រុមប្រឹក្សាឃុំមិនមានអំណាចប្រមូលពន្ធ ដូច្នេះសព្វថ្ងៃធនធានមូលដ្ឋានគឺសំដៅតែទៅលើប្រាក់វិភាគទានពីប្រជាពលរដ្ឋប៉ុណ្ណោះ(RGC ២០០៩) ។

ទោះបីជារបាយការណ៍របស់ខុមហ្វ្រែល ២០០៧បានបង្ហាញថា ក្រុមប្រឹក្សាឃុំនៅអាណត្តិទី១ ជួបបញ្ហានៅត្រង់ប្រាក់វិភាជន៍តិចតួច ប៉ុន្តែអាណត្តិទីពីរបានបង្ហាញពីកំរិតកើនឡើងនៃការផ្ទេរថវិកាទៅឲ្យក្រុមប្រឹក្សាឃុំ។ បើប្រៀបធៀបនឹងអាណត្តិទី១ ថវិការបស់ក្រុមប្រឹក្សាឃុំបានកើនពី ១.៥%នៅឆ្នាំ២០០២ រហូតដល់២.៨% នៅឆ្នាំ២០១០។ ជាសរុប ក្នុងរយៈពេល៤ឆ្នាំ (២០០៧-២០១០) មានថវិកា ចំនួន១៩៧លានដុល្លារសហរដ្ឋអាមេរិកត្រូវបានផ្ទេរទៅឲ្យក្រុមប្រឹក្សាឃុំ ដែលក្នុងនោះ៧៦% មកពីរាជរដ្ឋាភិបាល និងគំរោង PSDD/UNDP និង២៤% (៤៧លានដុល្លារសហរដ្ឋអាមេរិក) ពីដៃគូអភិវឌ្ឍផ្សេងទៀត។ ក្នុងចំណោមថវិកាសរុបនេះ មាន៦៧% វិភាជន៍សម្រាប់ការងារអភិវឌ្ឍន៍ និង៣៣% សម្រាប់កិច្ចការរដ្ឋបាល។ ក្នុងឆ្នាំ២០១២ ឃុំនិមួយៗទទួលថវិកាចំនួន ២៧.៥១៧ដុល្លារជាមធ្យម (RGC ២០១២)។ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តឲ្យមានការចូលរួមជាវិភាគទានមួយចំណែកនៃការចំណាយរបស់គម្រោងពីសំណាក់ប្រជាពលរដ្ឋ។ ពីឆ្នាំ២០០៧-

២០១០ វិភាគទានពីសំណាក់ប្រជាពលរដ្ឋ មានចំនួន១,៩លានដុល្លាសហរដ្ឋអាមេរិក (NCDD ២០១១) ។

ថវិកាក្រុមប្រឹក្សាឃុំ/សង្កាត់ បើទោះជាត្រូវបានគេបង្កើនជារៀងរាល់ឆ្នាំ ក៏មានចំនួនមិនទាន់គ្រប់គ្រាន់ដើម្បីឲ្យក្រុមប្រឹក្សាឃុំ ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋឲ្យមានប្រសិទ្ធិភាពឡើយ។ យោងទៅតាម Kim and Ojendal ២០០៧ នេះបង្ហាញថា ការកម្រិតនៃការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ និងធនធានដែលមាននៅមិនទាន់ស៊ីគ្នានៅឡើយ។ ថវិកាឃុំ/សង្កាត់មានកម្រិតមានន័យថា ក្រុមប្រឹក្សាឃុំត្រូវតែពឹងផ្អែកទៅលើថវិកាជំនួយពីខាងក្រៅ ដែលចំណុចនេះហើយបង្កើតឲ្យមានគណនេយ្យភាពផ្សេងទៀត។ ការសិក្សារបស់ Plummer and Tritt (២០១១) បានរកឃើញថាការផ្តល់ហិរញ្ញវត្ថុពីគណបក្សនយោបាយ ដើរតួនាទីយ៉ាងសំខាន់ចំពោះកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាន ជាពិសេសគឺនៅមុនពេលបោះឆ្នោត។ ឧទាហរណ៍ (Craig and Pak ២០១១) បានរកឃើញថា ការផ្តល់ហិរញ្ញវត្ថុពីគណបក្សនយោបាយនៅតំបន់សិក្សារបស់គេ គឺមានចំនួន២ ឬ៣ដងច្រើនជាងថវិកាក្រុមប្រឹក្សាឃុំ/សង្កាត់ដែលមាន។ ការផ្តល់ហិរញ្ញវត្ថុពីគណបក្សនយោបាយបណ្តាលឲ្យមានភាពអាប់ឱនផ្នែកនយោបាយដល់គណបក្សផ្សេង និងបង្កើតគណនេយ្យភាពនយោបាយ ដែលកន្លងមកថវិកាឃុំ/សង្កាត់ និងកម្មវិធីម្ចាស់ជំនួយនានា មិនធ្លាប់បង្កើតឲ្យមាននោះទេ។

## ៦.៦ ដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន

ដំណើរការនៃការធ្វើផែនការអភិវឌ្ឍន៍នៅថ្នាក់ឃុំផ្តោតជាសំខាន់លើកិច្ចការពីរ៖ (១) ការធ្វើផែនការអភិវឌ្ឍន៍ឃុំរយៈពេល៥ឆ្នាំ (CDP)និង (២) ការត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើផែនការវិនិយោគប្រចាំឆ្នាំរបស់ឃុំ (CIP)។ ដំណើរការលើកិច្ចការទាំងពីរនេះ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំភូមិ កិច្ចប្រជុំរបស់គណៈកម្មាធិការផែនការ និងថវិកា និងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ។

ដំណើរការនៃការធ្វើផែនការរបស់ក្រុមប្រឹក្សាឃុំ បង្ហាញនូវការចូលរួមកម្រិតណាមួយរបស់ប្រជាពលរដ្ឋ និងភាពជាដៃគូរវាងអ្នកពាក់ព័ន្ធ (Plummer and Tritt ២០១១) ។ សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកបង្ហាញពីការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល មន្ទីរជំនាញ និងក្រុមប្រឹក្សាឃុំក្នុងការចែករំលែកព័ត៌មានដើម្បីឆ្លើយតបនឹងចំណុចអាទិភាពរបស់ឃុំ។ ក្រុមប្រឹក្សាឃុំអាចធ្វើសំណើ និងអំពាវនាវសុំជំនួយគាំទ្រពីខាងក្រៅសម្រាប់ការអភិវឌ្ឍន៍ក្នុងឃុំរបស់ខ្លួនផងដែរ។

ទោះជាយ៉ាងណាក៏ដោយ មានបញ្ហាប្រឈមជាច្រើននៅតែកើតមានពាក់ព័ន្ធនឹងដំណើរការនៃការធ្វើផែនការនៅថ្នាក់ឃុំ៖

- សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំក្នុងការធ្វើផែនការ និងថវិកានៅតែជាបញ្ហា និងថវិកាក្រុមប្រឹក្សាឃុំសង្កាត់នៅតែមានកំរិតតិចតួច។ ទាំងអស់នេះដែលធ្វើឲ្យក្រុមប្រឹក្សាឃុំមានភាពស្ទាក់ស្ទើរក្នុងការជ្រើសរើសវិស័យ/សេវាកម្មជាអាទិភាព នៅក្នុងការធ្វើផែនការវិនិយោគរបស់ឃុំ ក្រៅពីជ្រើសរើសយកហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាផ្លូវលំជនបទ (Plummer and Tritt ២០១១)
- ប្រការដែលការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបនៅថ្នាក់ភូមិ និងឃុំបានធ្វើឲ្យមានភាពលំបាកដល់ក្រុមប្រឹក្សាឃុំក្នុងការធ្វើផែនការ និងការដាក់បញ្ចូលតម្រូវការមូលដ្ឋាន ទៅក្នុងរបៀបវារៈកិច្ចអភិវឌ្ឍន៍។ ខណៈដែលការធ្វើផែនការវិនិយោគថ្នាក់ឃុំទាមទារឲ្យមានប្រជាពលរដ្ឋចូលរួម៦០% ជាក់ស្តែងប្រជាពលរដ្ឋបានជ្រើសរើសមិនចូលរួម។ ប្រជា ពលរដ្ឋដែលចូលរួមភាគច្រើនជាស្រ្តី និងក្មេងជំទង់ដែលតែងតែសំដែងភាពអសកម្មនៅក្នុងកិច្ចប្រជុំ (Plummer and Tritt ២០១១) ។
- ផែនការដែលមានប្រសិទ្ធិភាព គួរអាចប្រែក្លាយទៅជាការអនុវត្តន៍ជាក់ស្តែងបាន។ បញ្ហាប្រឈមបច្ចុប្បន្នគឺនៅត្រង់ថាផែនការ និងការអនុវត្តន៍មិនស៊ីគ្នា។ ខណៈដែលការធ្វើផែនការបង្ហាញពីតម្រូវការមូលដ្ឋានពាក់ព័ន្ធនឹងសេវាសង្គម ការអនុវត្តន៍បែរផ្តោតខ្លាំងទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទៅវិញ។ ការធ្វើផែនការបានបង្កើតឲ្យមានការរំពឹងទុកខ្ពស់ពីសំណាក់ប្រជាពលរដ្ឋ ប៉ុន្តែវាបែរជាពុំមានផ្តល់លទ្ធផលដូចដែលប្រជាពលរដ្ឋរំពឹងទុក (Plummer and Tritt ២០១១) ។

## ៦.៧ ការផ្តល់សេវាកម្មសាធារណៈ

ការសម្រេចជាគន្លឹះរបស់ក្រុមប្រឹក្សាឃុំនៅក្នុងអាណត្តិទីពីរ គឺពាក់ព័ន្ធនឹងការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្លូវលំជនបទ (EIC 2010; Chheat, Lun et al. ២០១១) ។ ឧទាហរណ៍មានប្រជាពលរដ្ឋ៦០,៥% នៃ៨៥៣នាក់ ដែលអញ្ជើញមកពីឃុំដាច់ស្រយាល និងឃុំជនជាតិភាគតិចចំនួន៦៤ឃុំ ចូលរួមក្នុងសិក្ខាសាលាផ្តល់ពិន្ទុដែលរៀបចំដោយខុមហ្វ្រែល បានយល់ស្របថា យ៉ាងហោចណាស់ក្រុមប្រឹក្សាឃុំដែលបានជាប់ឆ្នោតក្នុងឃុំរបស់គាត់បានសង់ស្ពាន

និងផ្លូវថ្មីៗ ព្រមទាំងធ្វើការថែទាំផ្លូវលំ និងស្ពានទាំងនោះ (COMFREL ២០១៣)។ ប្រការដែលផ្លូវលំជនបទក្លាយជាជម្រើសវិនិយោគដ៏មានប្រជាប្រិយខ្លាំងបំផុតនោះ គឺពាក់ព័ន្ធនឹងហេតុផលជាច្រើន។ ក្រៅពីវាជាតម្រូវការមូលដ្ឋាន ការសម្រេចចិត្តក្នុងការជ្រើសរើសផ្លូវលំជនបទគឺពាក់ព័ន្ធនឹងហេតុផលសេដ្ឋកិច្ចនយោបាយ ដែលផ្លូវលំអាចជួយលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន។ ជ្រើសរើសផ្លូវលំជនបទក៏អាចឆ្លើយតបនឹងតម្រូវការមូលដ្ឋាន និងសមស្របនឹងសមត្ថភាពបច្ចេកទេស និងធនធានមានកម្រិតរបស់ឃុំ (Plummer and Tritt ២០១១) ។

ទោះបីជាក្រុមប្រឹក្សាឃុំចាប់អារម្មណ៍តែទៅលើការសាងសង់ផ្លូវលំជនបទ ក្រុមប្រឹក្សាឃុំពុំសូវសំដែងការចាប់អារម្មណ៍ទៅលើហេដ្ឋរចនាសម្ព័ន្ធផ្សេងទៀតដូចជាធារាសាស្ត្រ។ ឧទាហរណ៍លទ្ធផលនៃការផ្តល់ពិន្ទុរបស់អង្គការខុមហ្វ្រែលបានបង្ហាញថា មានប្រជាពលរដ្ឋ៥៦,៧% នៃ៤៣០ នាក់ដែលអញ្ជើញមកពីឃុំដាច់ស្រយាល និងឃុំជនជាតិភាគតិចបានអះអាងថា ពួកគេមិនយល់ស្របថាក្រុមប្រឹក្សាឃុំបានសាងសង់ស្ថានីយ៍បូមទឹក ជីក និងជួសជុលប្រឡាយទឹក ទ្វារទឹក ស្រះទំនប់ ឬប្រព័ន្ធបង្ហូរទឹកផ្សេងៗនៅក្នុងឃុំរបស់គេឡើយ (COMFREL ២០១៣)។ ក្រុមប្រឹក្សាឃុំធ្វើការវិនិយោគតិចតួចផ្នែកធារាសាស្ត្រ ដោយសារពួកគេព្រួយបារម្ភអំពីបញ្ហាហានិភ័យដែលបង្កដោយគម្រោង។ ធារាសាស្ត្រ គឺសមស្របសម្រាប់តែទីតាំងភូមិសាស្ត្រណាមួយ ហើយវិនិយោគក្នុងគម្រោងបែបនេះ តម្រូវឲ្យក្រុមប្រឹក្សាឃុំត្រូវធ្វើផែនការសម្រាប់ធនធានមនុស្សដែលមានជំនាញក្នុងការគ្រប់គ្រង ត្រួតត្រា និងថែទាំធារាសាស្ត្រ។ ផលប្រយោជន៍ពីការសង់ធារាសាស្ត្រ គឺបានតែប្រជាពលរដ្ឋទាំងឡាយណាដែលមានដីជិតប្រឡាយ មិនមែនបានដល់ប្រជាពលរដ្ឋទូទៅនោះឡើយ (Plummer and Tritt ២០១១) ។

ក្រៅពីការផ្តល់សេវាអគ្រានុកូលដ្ឋាន ក្រុមប្រឹក្សាឃុំក៏ខិតខំចុះអន្តរាគមន៍ក្នុងសេវាផ្សេងទៀត ដូចជាការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការជួសជុលសាលារៀន និងសេវាសុខភាពមាតា និងកុមារ អាហារូបត្ថម្ភ កិច្ចគាំពារកុមារ និងការគាំទ្រដល់គ្រួសារដែលងាយទទួលរងគ្រោះថ្នាក់។ ទោះជាយ៉ាងណាក៏ដោយ សេវាទាំងអស់នេះ គឺមិនសូវពេញនិយមក្នុងចំណោមក្រុមប្រឹក្សាឃុំឡើយ ពីព្រោះវាទាមទារឲ្យមានការចុះពិនិត្យតាមដាន និងការសម្របសម្រួលជាមួយក្រសួងជំនាញ ដែលនេះអាចបណ្តាលឲ្យមានភាពយឺតយ៉ាវ ឬការខ្វះបុគ្គលិកជំនាញចុះមកអនុវត្តការងារ (Plummer and Tritt 2011) ។

ការផ្តល់សេវារបស់ក្រុមប្រឹក្សាឃុំ គឺផ្អែកទៅលើចំណេះដឹងលើតម្រូវការប្រជាពលរដ្ឋ និងចំនួនថវិកាដែលមាន។ ដោយសារថវិកាក្រុមប្រឹក្សាឃុំ/សង្កាត់មានកម្រិតតិចតួច ឃុំពុំអាចផ្តល់សេវាឲ្យមានប្រសិទ្ធិភាពដល់ប្រជាពលរដ្ឋឡើយ ដូច្នេះឃុំត្រូវពឹងផ្អែកគណបក្សនយោបាយ និងសប្បុរសជន។ គេបានរកឃើញថា ថវិការបស់គណបក្សនយោបាយកន្លងមកបានចូលរួមយ៉ាងច្រើនដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ជាពិសេសសាលារៀន ធារាសាស្ត្រ និងផ្លូវលំជនបទ។ ការផ្តល់ថវិកាពីគណបក្សនយោបាយ គឺមិនដូចគ្នាគ្រប់ឃុំនោះទេ វាប្រែប្រួលទៅតាមជំនាញទំនាក់ទំនង និងបណ្តាញរបស់ក្រុមប្រឹក្សាឃុំ បុគ្គលិកលក្ខណៈ របស់មេឃុំនីមួយៗពាក់ព័ន្ធនឹងការអនុវត្តន៍ជាក់ស្តែង ការផ្តួចផ្តើមគំនិត ការចាត់ចែងក្នុងការប្រើប្រាស់ថវិកាផ្លូវការ និងមិនផ្លូវការសម្រាប់កិច្ចអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន (Heng, Kim et al. ២០១១) ព្រមទាំងទំនាក់ទំនងពិសេសរបស់ឃុំនីមួយៗជាមួយនឹងមេដឹកនាំនយោបាយ ថាតើតំបន់នោះជាស្រុកកំណើតរបស់ថ្នាក់ដឹកនាំនយោបាយណាមួយឬទេ ឬថាតើការផ្តល់ជំនួយដល់ឃុំនឹងអាចផ្តល់ជាមុខមាត់សាធារណៈដល់មេដឹកនាំនយោបាយនោះឬទេ (Craig and Pak ២០១១) ។

ទោះជាការផ្តល់ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ហាក់ដូចជាមានឥទ្ធិពលទៅលើការផ្តល់សេវាថ្នាក់មូលដ្ឋាន មានចំណុចខ្វះខាតមួយចំនួនត្រូវបានគេរកឃើញ។ ហិរញ្ញវត្ថុរបស់គណបក្សនយោបាយមានលក្ខណៈមិនទៀងទាត់ វាអាស្រ័យទៅលើវដ្តនៃការបោះឆ្នោត និងភាគច្រើនគឺផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាការសាងសង់សាលារៀន ប៉ុន្តែពុំបានផ្តោតទៅលើការលើកទឹកចិត្តគ្រូបង្រៀនឲ្យចុះ និងធ្វើការបង្រៀនទៀងទាត់នោះទេ។ ការផ្តោតតែទៅលើហេដ្ឋារចនាសម្ព័ន្ធ ភ្លេចគិតទៅលើការថែទាំតែងតែធ្វើឲ្យការវិនិយោគទាំងនោះពុំសូវមាននិរន្តរភាព ឧទាហរណ៍ ករណីផ្លូវលំជនបទ(Craig and Pak ២០១១) ។

អាណត្តិទីពីររបស់ក្រុមប្រឹក្សាឃុំ បានបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំក្នុងកិច្ចការពារធនធានធម្មជាតិសម្រាប់ផលប្រយោជន៍ប្រជាពលរដ្ឋ។ មានការសិក្សាមួយចំនួន (Heng, Kim et al. ២០១១; Plummer and Tritt ២០១១; NCDD ២០១២) បានរកឃើញថាប្រជាពលរដ្ឋបានសំដែងភាពមិនពេញចិត្តទៅលើការអនុវត្តរបស់ក្រុមប្រឹក្សាឃុំលើវិស័យនេះទេ។ ការសិក្សាស្ទង់មតិរបស់ (NCDD ២០១២) បានបង្ហាញថាប្រជាពលរដ្ឋបានចាត់ទុកថាការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំនៅមានកម្រិតទាបក្នុងការពារធនធានព្រៃឈើ និងជលផល។

Plummer and Tritt (២០១១) បានអះអាងថា ក្រុមប្រឹក្សាឃុំមិនអាចជាអ្នកដែលទទួលការស្តីបន្ទោសលើបញ្ហានេះទាំងអស់នោះទេ។ ភាពមិនពេញចិត្តរបស់ប្រជាពលរដ្ឋលើចំណុចនេះមិនមែនមានន័យថា ក្រុមប្រឹក្សាឃុំពុំអាចអនុវត្តកិច្ចការពារធនធានធម្មជាតិឲ្យបានល្អនោះទេ។ ហេតុផលដែលនាំឲ្យក្រុមប្រឹក្សាឃុំបរាជ័យ គឺពាក់ព័ន្ធនឹងភាពមានកម្រិតនៃតួនាទី និងសមត្ថកិច្ចរបស់ឃុំក្នុងការការពារធនធានធម្មជាតិ ដែលចំណុចនេះធ្វើឲ្យឃុំពុំអាចចុះអន្តរាគមន៍ជួយប្រជាពលរដ្ឋបាន។ ក្នុងករណីសិក្សាមួយចំនួន Plummer and Tritt (២០១១) បានរកឃើញថា ក្រុមប្រឹក្សាឃុំបានព្យាយាមដោះស្រាយជម្លោះដីធ្លី ប៉ុន្តែការអនុវត្តន៍បែបនេះតែងតែបង្កឲ្យមានការខាតបង់ដល់ខ្លួនឯងវិញ។ ក្រុមប្រឹក្សាឃុំជួបនូវវិបត្តិក្នុងការអនុវត្តន៍គណនេយ្យភាពទៅថ្នាក់លើផង និងទៅប្រជាពលរដ្ឋផង។

## ៦.៨ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ

កម្រិតវប្បធម៌របស់ក្រុមប្រឹក្សាឃុំ នៅក្នុងអាណត្តិទីពីរនេះនៅមានកំរិតទាបនៅឡើយ។ ការសិក្សាស្ទង់មតិរបស់ CDRI នៅឆ្នាំ២០១១ បានបង្ហាញថា ជាងពាក់កណ្តាលនៃក្រុមប្រឹក្សាឃុំដែលបានសម្ភាស (៥៥% ក្នុងចំណោម៥៣១នាក់) មានកម្រិតវប្បធម៌ពី១-៦ឆ្នាំ ៣០% ពី៧-៩ឆ្នាំ ១៣% ពី១០-១២ឆ្នាំ និងមានតែ២% ចាប់ពី១៣ឆ្នាំឡើងទៅ។ យោងទៅតាម Thon et al (២០០៩) កម្រិតវប្បធម៌ទាបរបស់ក្រុមប្រឹក្សាឃុំមិនគួរជាចំណុចភ្ញាក់ផ្អើលឡើយ ដោយហេតុថា ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១បានចែងថា ប្រជាពលរដ្ឋខ្មែរដែលចេះអាន ចេះសរសេរខ្មែរគឺមានសិទ្ធិស្របច្បាប់ឈរឈ្មោះសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ ដូច្នេះមានន័យថាកម្រិតវប្បធម៌ត្រឹមបឋមសិក្សាគឺសមស្របសម្រាប់ថ្នាក់ក្រុមប្រឹក្សាឃុំ។

ខណៈដែលកម្រិតវប្បធម៌ទាបគឺជាបញ្ហារបស់ក្រុមប្រឹក្សាឃុំ Plummer & Tritt (២០១១) បានរកឃើញផងដែរថា សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំលើការធ្វើផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។ ដោយសារកម្រិតវប្បធម៌ទាប ក្រុមប្រឹក្សាឃុំមានការលំបាកក្នុងការចាប់យកចំណេះដឹង ជាហេតុធ្វើឲ្យក្រុមប្រឹក្សាឃុំត្រូវពឹងផ្អែកទៅលើស្មៀន ដែលជាបេក្ខជនជ្រើសតាំង និងទទួលបានបទពិសោធន៍ជាច្រើនពីក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងគម្រោងបច្ចេកទេសស្មុគស្មាញនានា។

កម្រិតវប្បធម៌ទាបមិនមានន័យថា ក្រុមប្រឹក្សាឃុំមិនមានសមត្ថភាពគ្រប់គ្រងរដ្ឋបាលរបស់ខ្លួននោះទេ។ Öjendal & Kim (២០១១) បានបង្ហាញថា ទោះជាក្រុមប្រឹក្សាឃុំមានកម្រិតវប្បធម៌ទាបក្តី តែពួកគាត់មានចំណេះដឹងគ្រប់គ្រាន់ពាក់ព័ន្ធនឹងស្ថានភាពមូលដ្ឋាន ពីព្រោះពួកគាត់រស់នៅក្នុងតំបន់នោះ។ Thon et al (២០០៩) បានរកឃើញថា ក្រុមប្រឹក្សាដែលបានសម្ភាសន៍ភាគច្រើនសុទ្ធតែមានបទពិសោធន៍ក្នុងការគ្រប់គ្រងរដ្ឋបាល ពីព្រោះពួកគាត់ធ្លាប់កាន់មុខតំណែងសាធារណៈតាំងពីឆ្នាំ១៩៧៩ ឬក្នុងរបបខ្មែរក្រហមមកម្ល៉េះ។ ដូចគ្នាដែរ ភាពជាអ្នកដឹកនាំ ភាពស្របច្បាប់ និងសមត្ថភាពរបស់ខ្លួនបានធ្វើឲ្យពួកគាត់មានបណ្តាញទំនាក់ទំនងនៅក្នុងការងារ។ ភាពបរាជ័យក្នុងការដឹកនាំរបស់ក្រុមប្រឹក្សាឃុំអាចបណ្តាលមកពីកត្តាផ្សេង មិនមែនកំណត់តែទៅលើកម្រិតវប្បធម៌នោះទេ គឺអាចមកពីកង្វះធនធានហិរញ្ញវត្ថុ និងកង្វះខាតនយោបាយនៅក្នុងអាណត្តិរបស់ខ្លួនក្នុងការអនុវត្តន៍នយោបាយបែបគាំទ្រសកម្មក្នុងការជួយការពារប្រជាពលរដ្ឋ (Kim and Öjendal ២០០៧)។

បើទោះជាកំរិតវប្បធម៌នៅមានកម្រិត ក្រុមប្រឹក្សាឃុំមានជំនឿទុកចិត្តខ្ពស់លើខ្លួនឯង ក្នុងការថែរក្សាគណនេយ្យភាពទៅកាន់ប្រជាពលរដ្ឋ (EIC ២០១០) ដោយសារបទពិសោធន៍ ពីអាណត្តិទីមួយ។ ទោះជាយ៉ាងណាក៏ដោយ ការបណ្តុះបណ្តាលគឺនៅតែមានសារៈសំខាន់ដើម្បីពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំចាស់ និងថ្មីដែលទើបជាប់ឆ្នោតលើកតំបូង។ មានក្រុមប្រឹក្សាឃុំចំនួន ៤០,៩៩%ឆ្នាំ២០០៧-២០១១ ដែលជាប់ឆ្នោតលើកតំបូង។ ការបណ្តុះបណ្តាលនឹងអាចជួយបន្ថែមចំណេះដឹងដល់ក្រុមប្រឹក្សាឃុំចាស់ (អ្នកដែលធ្លាប់ជាប់អាណត្តិមុន) ឲ្យអនុវត្តតួនាទីរបស់ខ្លួនកាន់តែមានប្រសិទ្ធិភាពថែមទៀត។

របាយការណ៍របស់ ខុមប្រែល ឆ្នាំ២០០៧ បានបង្ហាញថា វគ្គបណ្តុះបណ្តាលដែលផ្តល់ដល់ក្រុមប្រឹក្សាឃុំមានចំនួនច្រើនខ្លាំង មានលក្ខណៈទូលំទូលាយពេក និងមិនសូវផ្តោតជាសំខាន់ដល់ស្ថានភាពនៅថ្នាក់មូលដ្ឋាន។ ដើម្បីដោះស្រាយបញ្ហានេះ នៅក្នុងអាណត្តិទីពីរ គ.ជ.អ.ប បានធ្វើការសិក្សាស៊ីជំរៅមួយអំពីតម្រូវការផ្នែកការបណ្តុះបណ្តាលសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ដើម្បីកំណត់រកមេរៀន យុទ្ធសាស្ត្រ ថវិកា និងភ្នាក់ងារដែលទទួលខុសត្រូវសម្រាប់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ (NCDD 2011)។ ជាលទ្ធផល មេរៀនសម្រាប់ការបណ្តុះបណ្តាលត្រូវបានគេរៀបចំ និងផ្តល់ជូនដល់ក្រុមប្រឹក្សាឃុំ។ តារាងខាងក្រោមបង្ហាញអំពីមេរៀនសម្រាប់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំពីឆ្នាំ២០០៧២០១០។

## តារាង៖ មេរៀនសម្រាប់វគ្គបណ្តុះបណ្តាលទៅកាន់ក្រុមប្រឹក្សាឃុំ ២០០៧-២០១០

| ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|
| • ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់<br>• ការធ្វើផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់<br>• សកម្មភាពបង្ការមេរោគអេដស៍ និងជម្ងឺអេដស៍របស់ឃុំ/សង្កាត់នៅក្នុងសហគមន៍<br>• យេនឌ័រសម្រាប់រដ្ឋបាលមូលដ្ឋាន | • ការសម្របសម្រួលជម្លោះ<br>• ការអនុវត្តន៍មុខងាររបស់គណៈកម្មាធិការកិច្ចការស្ត្រី និងកុមារ<br>• ការត្រួតពិនិត្យសៀវភៅចុះឈ្មោះ | • ការអនុវត្តន៍ថវិកាឃុំ/សង្កាត់<br>• ការត្រួតពិនិត្យ និងវាយតម្លៃកិច្ចការហិរញ្ញវត្ថុ និងរដ្ឋបាលនៅថ្នាក់ឃុំ/សង្កាត់<br>• ភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់<br>• ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ<br>• ការរៀបចំសម្រាប់ការផ្ទេរតួនាទី និងការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុកនិងខណ្ឌចាស់<br>• គោលការណ៍មូលដ្ឋានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | • គំនិតអភិវឌ្ឍន៍សម្រាប់ឃុំ/សង្កាត់<br>• សកម្មភាពរបស់ឃុំ/សង្កាត់សម្រាប់ការអភិវឌ្ឍន៍សង្គម<br>• ការសរសេររបាយការណ៍ខ្នាតតូច<br>• ការអនុវត្តន៍មុខងាររបស់គណៈកម្មាធិការកិច្ចការស្ត្រី និងកុមារសម្រាប់ការអភិវឌ្ឍន៍សង្គម<br>• ការបញ្ចូលរចនាសម្ព័ន្ធរបស់មន្ត្រីរាជការស៊ីវិលនៅរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌទៅក្នុងរចនាសម្ព័ន្ធថ្មី<br>• តួនាទី ការទទួលខុសត្រូវ និងនិតិវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ការផ្សព្វផ្សាយស្តីពីអនុក្រិត្យ និងប្រកាសដើម្បីគាំទ្រការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ |

ប្រភព (NCDD ២០១១)

# ៧. ការចូលរួមរបស់ប្រជាពលរដ្ឋ

ខុមប្រែលបានរាយការណ៍ថា ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបនៅក្នុងអាណត្តិទីមួយនៃក្រុមប្រឹក្សាឃុំសង្កាត់។ ដូចគ្នាដែរនៅក្នុងរបាយការណ៍ EIC *២០១០* និង Plummer and Tritt ២០១១ បានរកឃើញថា ទោះបីជាប្រជាពលរដ្ឋហាក់បីដូចជាបានសម្តែងការយល់ដឹងកាន់តែប្រសើរស្តីអំពីសេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមជាសមាជិកក្រុមនៅក្នុងអង្គការនានា ឬសហគមន៍ក៏ដោយ នៅក្នុងអាណត្តិទីពីរនេះ ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបដដែល ជាពិសេសនៅក្នុងការរៀបចំថវិកា និងធ្វើផែនការរបស់ឃុំសង្កាត់។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា ការចូលរួមរបស់ប្រជាពលរដ្ឋបែរជាមានកម្រិតខ្ពស់នៅក្នុងដំណាក់កាលចាំបាច់ ។ បញ្ហានេះនឹងត្រូវបកស្រាយលម្អិតនៅក្នុងផ្នែកខាងក្រោម ។

គេសង្កេតឃើញថា នៅក្នុងការប្រជុំនៅតាមភូមិ ឃុំ គឺមានការចូលរួមតិចតួចនៅឡើយទាំងគុណភាពនិងបរិមាណ។ នៅក្នុងការសិក្សាស្ទាបស្ទង់មតិធ្វើឡើងដោយ EIC នៅក្នុងឆ្នាំ២០១០ បានបង្ហាញថា មានអ្នកភូមិ៥១% តែប៉ុណ្ណោះដែលបានចូលរួមក្នុងការប្រជុំផែនការតាមភូមិ។ ដែលក្នុងនោះពួកគាត់ហាក់បីដូចជាពុំមានឆន្ទៈក្នុងការចូលរួមទេ ពីព្រោះពួកគាត់ចូលរួមការប្រជុំនេះតាមការណែនាំ និងចង្អុលបង្ហាញពីមេភូមិប៉ុណ្ណោះ។ ឧទាហរណ៍ជាក់ស្តែងគឺ អ្នកភូមិ៧៧% ដែលបានចូលរួមការប្រជុំបាននិយាយថា ពួកគាត់ចូលរួមការប្រជុំនេះដោយសារតែមានការប្រាប់ពីអាជ្ញាធរ និង១៨%ទៀត បានមានប្រសាសន៍ថា ពួកគាត់ចូលរួមការប្រជុំភូមិ ឃុំ ដោយសារតែពួកគាត់ត្រូវបានគេអញ្ជើញផ្ទាល់។

តាមពិតទៅការប្រជុំថ្នាក់ភូមិត្រូវបានគេចាត់ទុកថា ជាវេទិកាមួយដែលអ្នកភូមិអាចចូលរួមចំណែកផ្តល់មតិយោបល់ និងលើកឡើងនូវតម្រូវការរបស់ពួកគាត់នៅក្នុងសកម្មភាពអភិវឌ្ឍនានានៅក្នុងភូមិឃុំរបស់ពួកគាត់។ នៅក្នុងការប្រជុំថ្នាក់ភូមិមួយគឺតម្រូវឱ្យមានការចូលរួមយ៉ាងតិចណាស់៦០% នៃអ្នកភូមិសរុប ប៉ុន្តែតាមភាពជាក់ស្តែងមេភូមិជារឿយៗមិនអាចរកបានតាមចំនួនសមាមាត្រនេះទេ ដែលនៅទីបញ្ចប់ការប្រជុំនេះមានតែអ្នកភូមិតិចតួចប៉ុណ្ណោះដែលបានចូលរួម។ បើយោងទៅតាមការស្រាវជ្រាវរបស់ Plummer and Tritt នៅក្នុងឆ្នាំ២០១១បានរកឃើញថានៅក្នុងការប្រជុំថ្នាក់ភូមិមានកង្វះខាតចំពោះការប្រមូលអ្នកភូមិចូលរួមប្រជុំ ហើយមេភូមិបានប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយព័ត៌មានតែមួយវិធីតែប៉ុណ្ណោះ។ ការចូលរួមប្រជុំថ្នាក់ភូមិ គឺមិនសូវមានការ

បញ្ចេញមតិយោបល់នោះទេ នេះបើប្រៀបធៀបទៅនឹងការប្រជុំដែលរៀបចំឡើងដោយអង្គការ និងគណបក្សនយោបាយនានា។ មូលហេតុចំបងពីបញ្ហានេះគឺបណ្តាលមកពីកង្វះខាតការលើកទឹកចិត្តក្នុងការចូលរួមចំណែក និងជំនាញការរៀបចំការប្រជុំ ។ ការប្រជុំថ្នាក់ភូមិ គឺត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីផ្តល់ព័ត៌មាន ជាជាងបំផុសឱ្យអ្នកភូមិចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ យោងតាមការស្រាវជ្រាវរបស់ Plummer and Tritt នៅក្នុងឆ្នាំ២០១១បានបង្ហាញថាមូលហេតុដែលបង្កឱ្យមានបញ្ហានេះគឺពីព្រោះមានតែមន្ត្រីថ្នាក់ឃុំតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្ត។

បើតាមរបាយការណ៍ EIC ឆ្នាំ២០១០ បានឱ្យដឹងថា ការចូលរួមក៏មានកម្រិតទាបផងដែរនៅក្នុងការប្រជុំក្រុមប្រឹក្សាឃុំ ឬការប្រជុំផ្សេងៗទៀត។ ឧទាហរណ៍ៈការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍ដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ គឺនៅមានកម្រិតទាបផងដែរ។ បើយោងតាម Thon et al. ឆ្នាំ២០០៩ នៅក្នុងករណីមួយក្នុងចំណោមករណីជាច្រើន ការចូលរួមត្រូវបានធ្លាក់ចុះដល់កម្រិតមួយដែលថាក្រុមប្រឹក្សាឃុំត្រូវជួលឧឃោសនស័ព្ទដើម្បីជាការផ្សព្វផ្សាយព័ត៌មានជំនួសការប្រជុំ។ តាមការស្ទង់មតិមួយដែលធ្វើឡើងដោយ EIC ឆ្នាំ២០១០ បានរកឃើញថា ៨៧% នៃអ្នកដែលបានសម្ភាសន៍ និង៩២% នៃប្រជាជនក្រីក្រមិនបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សានៅក្នុងឆ្នាំកន្លងផុតទៅនោះទេ។ តាមការស្ទាបស្ទង់មតិមួយផ្សេងទៀតដែលធ្វើឡើងដោយខុមហ្វ្រែលនៅក្នុងឆ្នាំ ២០១១ ក៏បានបង្ហាញដែរថា មានតែ៣៣.៧០% នៃអ្នកដែលបានសម្ភាសន៍ ធ្លាប់ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សានៅក្នុងអាណត្តិទី២នៃក្រុមប្រឹក្សាឃុំ។ ហើយបើតាមការស្ទាបស្ទង់មតិចុងក្រោយ ដោយ គ.ជ.អ.ប ឆ្នាំ២០១២ វិញបានឱ្យដឹងថា មានតែ៤០.៧០% នៃអ្នកដែលបានសម្ភាសន៍ក្នុងចំណោម ១៩១២នាក់បានអះអាងថា ពួកគាត់បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា ។

នៅក្នុងរបាយការណ៍របស់ Malena និង Chhim ២០០៩ និងខុមហ្វ្រែល ២០១១បានបញ្ជាក់ដូចគ្នាថា អ្នកភូមិដែលបានចូលរួមការប្រជុំនេះគឺគ្រាន់តែស្តាប់តែប៉ុណ្ណោះ ប៉ុន្តែពួកគាត់ពុំបានធ្វើការទាមទារ ឬ លើកឡើងពីបញ្ហាដែលពួកគាត់បានជួបប្រទះនោះទេ ។ គ.ជ.អ.ប ក៏បានរកឃើញថាមានតែ២៨.៤០% នៃអ្នកដែលចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា ធ្លាប់ចូលរួមចំណែកក្នុងការបញ្ចេញមតិយោបល់។ គេក៏កត់សម្គាល់ឃើញដែរថា មនុស្សវ័យជំទង់មិនសូវចូលរួម និងបញ្ចេញមតិនៅក្នុងអង្គប្រជុំដូចចាស់ៗទេ ។ ទន្ទឹមនឹងនោះដែរ របាយការណ៍ EIC ឆ្នាំ២០១០ បានបង្ហាញថា ការចូលរួមនៅមានកម្រិតទាបនេះគឺបណ្តាលមកពីកត្តាមួយចំនួនដូចជាៈ កង្វះខាតនៃការចាប់អារម្មណ៍របស់ប្រជាជនទៅលើកិច្ចការងារក្រុមប្រឹក្សាឃុំ កត្តាសេដ្ឋកិច្ច និងវប្បធម៌ (តាមរបាយការណ៍ខុម

ប្រៀវល 2011; Heng, Kim et al. 2011; Kim 2011) និងកង្វះខាតព័ត៌មានស្តីពីការប្រជុំ ការលើកទឹកចិត្ត និងលទ្ធផលក្នុងការចូលរួមប្រជុំ (តាមរបាយការណ៍ខុមប្រៀវល 2011) ។ តាមការពិតទៅ ក្រុមប្រឹក្សាឃុំមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកភូមិនោះ គឺបណ្តាលមកពីថវិកាឃុំសង្កាត់មានកម្រិត ដែលធ្វើឱ្យអ្នកភូមិបាត់បង់ឆន្ទៈក្នុងការចូលរួមប្រជុំថ្នាក់ភូមិ (នេះបើតាមរបាយការណ៍របស់ Heng, Kim et al. 2011)។ ការចូលរួមប្រជុំ គឺអាស្រ័យទៅលើថាតើអ្នកណា ជាអ្នករៀបចំការប្រជុំ។ បើយើងប្រៀបធៀបទៅនឹងការប្រជុំដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយនានាវិញ គឺមានអ្នកភូមិចូលរួមច្រើនជាង ដោយសារតែមានការផ្តល់អំណោយ និងអាហារសម្រន់ផ្សេងៗ ។

Plummer និង Tritt ២០១១ ក៏បានបង្ហាញថា ការចូលរួមប្រជុំហាក់ដូចជាត្រូវបានគេដាក់កម្រិតនៅពេលដែលការប្រជុំនោះពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចចិត្ត។ បើទោះបីជាច្បាប់ឃុំសង្កាត់បាននិយាយថា ការប្រជុំថ្នាក់ឃុំ សង្កាត់ត្រូវតែបើកចំហដល់សាធារណជនចូលរួមក៏ដោយ តែបើតាមភាពជាក់ស្តែង ការប្រជុំនេះគឺបើកចំហចំពោះតែអ្នកដែលត្រូវបានអញ្ជើញតែប៉ុណ្ណោះ ដូចជាមេភូមិ ឬមន្ត្រីគាំទ្របច្ចេកទេស (តាមរបាយការណ៍ Meerkerrk, Hean et al. 2008; Malena and Chhim 2009)។ ចំណែកឯរបាយការណ៍ Plummer និង Tritt ២០១១ ក៏បានបញ្ជាក់ដែរថា បើទោះបីជាអ្នកភូមិ ត្រូវបានគេអនុញ្ញាតឱ្យចូលរួមការប្រជុំក្រុមប្រឹក្សានៅតាមឃុំ សង្កាត់មួយចំនួន ក៏ដោយ ក៏ឱកាសសម្រាប់ពួកគាត់ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនៅមានកម្រិតនៅឡើយ។ ប៉ុន្តែជាទូទៅការប្រជុំក្រុមប្រឹក្សានេះត្រូវបានគេរាយការណ៍ថា បានផ្តល់ឱកាសដល់មេភូមិដើម្បីពិភាក្សាពីការវិវឌ្ឍន៍នៃផែនការ និងបញ្ហាផ្សេងៗទៀតដែលទាក់ទិនទៅនឹងការអនុវត្តន៍ផែនការនៅក្នុងឃុំសង្កាត់របស់ពួកគាត់ ប៉ុន្តែគេសង្កេតឃើញថាឱកាសដែលមេភូមិក្នុងការបញ្ចេញមតិពីតម្រូវការរបស់អ្នកភូមិនោះ គឺនៅមានកម្រិតនៅឡើយ។ ជាទូទៅការប្រជុំនេះ គឺត្រូវបានគ្រប់គ្រងដោយមេឃុំ ជាពិសេសពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចចិត្ត និងការលើកមតិយោបល់ (ដកស្រង់ចេញពីរបាយការណ៍ Plummer and Tritt ២០១១) ។

របាយការណ៍របស់ (Thon, Ou et al. 2009; EIC 2010) បានគូសបញ្ជាក់ថាខណៈដែលការចូលរួមប្រជុំផ្លូវការពីសំណាក់អ្នកភូមិគឺនៅមានកម្រិតទាប អ្នកភូមិហាក់ដូចជាចូលចិត្តលើកពីតម្រូវការរបស់ពួកគាត់ទៅមេភូមិ ឬចាស់ទុំនៅក្នុងភូមិដែលពួកគាត់អាចលើកពីបញ្ហានេះបន្តទៅក្រុមប្រឹក្សាឃុំវិញ។ របាយការណ៍របស់ Plummer and Tritt (២០១១) បានបកស្រាយថា បញ្ហានេះគឺ

មួយផ្នែកមកពីប្រជាជនកម្ពុជានៅមិនទាន់ស៊ាំ ទៅនឹងការនិយាយទៅកាន់មន្ត្រីដែលមានឋានៈខ្ពស់ជាងខ្លួន។ បើយោងតាមរបាយការណ៍ EIC (២០១០) បានឱ្យដឹងថា អ្នកភូមិ៣៥% បានអះអាងថាពួកគាត់ បានទាក់ទងមេភូមិដើម្បីបញ្ចេញមតិយោបល់របស់ពួកគាត់យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ និងអ្នកភូមិ៥៤% ទៀតបានទាក់ទងចាស់ទុំក្នុងភូមិ។ របាយការណ៍របស់ Plummer និង Tritt (២០១១) និង ធន និងផ្សេងទៀត (២០០៩) ក៏បានរកឃើញដូចគ្នាដែរថាព័ត៌មានដែលបានប្រាប់ទៅចាស់ទុំក្នុងភូមិ ហាក់បីដូចជាមធ្យោបាយដ៏មានប្រសិទ្ធភាពទៅលើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ ពីព្រោះក្រុមប្រឹក្សាឃុំទំនងជាគោរពចាស់ទុំក្នុងភូមិចំពោះការសម្រេចចិត្តដើម្បីការអភិវឌ្ឍន៍ក្នុងសហគមន៍។ ចាស់ទុំក្នុងភូមិអាចរួមមានដូចជាអ្នកដែលមានអាយុចំណាស់ ប៉ុន្តែទទួលបានការគោរពភាគច្រើនពីអ្នកភូមិ ឬអ្នកដែលមានទ្រព្យសម្បត្តិច្រើន ឬអ្នកដែលមានទំនាក់ទំនងជាមួយគណបក្សប្រជាជនកម្ពុជា នេះបើតាមរបាយការណ៍របស់ Plummer និង Tritt ២០១១។

គួរឱ្យចាប់អារម្មណ៍ផងដែរនោះ គឺគេក៏បានរកឃើញថាក្នុងអំឡុងពេលចាំបាច់ កម្រិតនៃការចូលរួមមានការកើនឡើងខ្ពស់ ដែលអ្នកភូមិបានប្រមូលផ្តុំ និងលើកឡើងពីតម្រូវការរបស់ពួកគាត់ផ្ទាល់ទៅដល់ក្រុមប្រឹក្សាឃុំចំពោះបញ្ហាដែលពួកគាត់មាន។ របាយការណ៍របស់ Plummer និង Tritt (២០១១) បានកត់សម្គាល់ផងដែរថា អ្នកភូមិមាននិន្នាការប្រមូលផ្តុំគ្នា និងការពារចំណាប់អារម្មណ៍របស់ពួកគេនៅពេលដែលក្រុមប្រឹក្សាឃុំមិនគោរពពាក្យសន្យារបស់ខ្លួន នៅពេលដែលការបង់ថ្លៃវិភាគទានរបស់ពួកគាត់ទៅលើផែនការមិនបានផ្តល់លទ្ធផលអ្វីទាំងអស់ និងនៅពេលដែលអ្នកភូមិមានអារម្មណ៍ថា មានភាពអយុត្តិធម៌ ឧទាហរណ៍ៈ ករណីជម្លោះដីធ្លី ។ ការកើតមានឡើងនូវបញ្ហាទុក្ខព្រួយនៅថ្នាក់មូលដ្ឋាន បានបង្ហាញពីការរើបំរាស់ពីសំណាក់ប្រជាពលរដ្ឋ ដែលនេះជាសមិទ្ធិផលដែលវិមជ្ឈការខិតខំអនុវត្តកន្លងមក។

# ៨. បញ្ហាកើតឡើងថ្មីៗ

## ៨.១ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក)

គណៈកម្មាធិការស្ត្រី និងកុមារ បានបង្កើតឡើងដំបូងក្នុងឆ្នាំ ២០០៤ តែមិនទាន់ មាននៅគ្រប់ឃុំទាំងអស់នោះទេ។ រហូតដល់ឆ្នាំ ២០០៧ ក្រសួងមហាផ្ទៃបានធ្វើការណែនាំឲ្យឃុំទាំងអស់បង្កើតគណៈកម្មាធិការនេះ។ ជាលទ្ធផល គ.ជ.អ.ប បានចេញ សេចក្តីណែនាំលេខ ០៨២ នៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០៧ ដើម្បីបង្កើត គ.ក.ន.ក នៅក្នុងឃុំចំនួន ១,៦២១ ទូទាំងប្រទេស។

គ.ក.ន.ក មានតួនាទីផ្តល់យោបល់ណែនាំ សម្របសម្រួល និងរាយការណ៍ដល់ក្រុមប្រឹក្សាឃុំ ដើម្បីធ្វើយ៉ាងណាឲ្យស្ត្រី និងកុមារទទួលបានសេវាសមរម្យ និងមានប្រយោជន៍ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ សមាជិករបស់ គ.ក.ន.ក រួមមាន ក្រុមប្រឹក្សាឃុំ (មេឃុំ ជំទប់ និងស្មៀនឃុំ) និងអ្នកទទួលបន្ទុកការងារស្ត្រី និងកុមារ។ អ្នកទទួលបន្ទុកការងារស្ត្រី និងកុមារ អាចជាសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ឬតាមរយៈការជ្រើសរើសរបស់មេឃុំ។ ក្រៅពីនេះ ក៏មានតំណាងផ្សេងៗមកពីមណ្ឌលសុខភាព សាលាកម្រង នគរបាល និងមេភូមិ។

លទ្ធផលពីការស្ទង់មតិ បានបង្ហាញពីឥទ្ធិពលជាវិជ្ជមានរបស់គ.ក.ន.ក។ ឃុំដែលមាន គ.ក.ន.ក បានផ្តល់អាទិភាពទៅដល់បញ្ហាស្ត្រី និងកុមារច្រើនជាងឃុំដែលទើបតែមាន ឬគ្មាន គ.ក.ន.ក។ គ.ក.ន.ក បានបញ្ចូលបញ្ហាស្ត្រី និងកុមារទៅក្នុងរបៀបវារៈប្រជុំរបស់ក្រុមប្រឹក្សាឃុំ ក៏ដូចជាទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។ បន្ថែមពីលើនេះ គ.ក.ន.ក បានពង្រីកតួនាទីរបស់ឃុំ ដោយធ្វើឲ្យប្រសើរឡើងនូវការទទួលបានសេវាសង្គម។ សមាជិករបស់ គ.ក.ន.ក ក៏បានដើរតួនាទីជាអ្នកតស៊ូមតិលើបញ្ហាស្ត្រី និងកុមារនៅក្នុងឃុំរបស់ខ្លួន។

លើសពីនេះ នៅក្នុងឆ្នាំ២០១១ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំមួយដល់ឃុំសង្កាត់ឲ្យយកចិត្តទុកដាក់លើ គ.ក.ន.ក និងវិភាជន៍ថវិកាឃុំឲ្យទៅ គ.ក.ន.ក។ គ.ក.ន.ក នឹងបន្តដើរតួនាទីនៅថ្នាក់ឃុំលើបញ្ហាទាក់ទងស្ត្រី និងកុមារ។ ជាមួយគ្នានេះផងដែរ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ (គ.ព.ស.ក) ក៏ត្រូវបានបង្កើតឡើងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនឹងកុមារក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០០៨។

## ៨.២ ការផ្ដោតលើការប្រែប្រួលអាកាសធាតុនៅថ្នាក់ឃុំ សង្កាត់

ការបន្សុាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ គឺជាការងារអន្តរវិស័យ ដែលជះឥទ្ធិពលភាគច្រើនដល់តំបន់ជនបទ។ ប្រទេសកំពុងអភិវឌ្ឍ ដែលរួមមានប្រទេសកម្ពុជាផងដែរ ងាយទទួលរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ដោយសារតែប្រជាជនភាគច្រើនក្រីក្រ ហេដ្ឋារចនាសម្ព័ន្ធមិនសូវរឹកចម្រើន រីឯចំណេះដឹងទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងផលវិបាករបស់វាក៏នៅមានកម្រិត។ ហេតុនេះ វាចាំបាច់តម្រូវឲ្យមានការពិភាក្សាទាក់ទងនឹងការប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន។ វាប្រហែលជាលឿនពេកដែលតម្រូវឲ្យ NCDD-S ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ចេញគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ប៉ុន្តែយ៉ាងហោចណាស់ NCDD-S អាចពិចារណាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តដាក់លើបញ្ហានៃការប្រែប្រួលអាកាសធាតុ និងផលវិបាកពីការប្រែប្រួលនេះ (NCDD Forthcoming)។

ថ្មីៗនេះ ដោយមានការគាំទ្រពីមូលនិធិអភិវឌ្ឍន៍ទុនសហប្រជាជាតិ (UNCDF) រដ្ឋបាលថ្នាក់ក្រោមជាតិបានត្រៀមរៀបចំបញ្ចូលការបន្សុាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការសកម្មភាពរបស់ខ្លួន និងមានការកសាងសមត្ថភាពនៅមូលដ្ឋានផងដែរ។ គម្រោងនេះមានលក្ខណៈជាការសាកល្បងនៅឡើយ។

## ៨.៣ ការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

សិក្ខាសាលាពិគ្រោះយោបល់ដោយមានការសម្របសម្រួលពីសម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ ២០១២ ដើម្បីពិភាក្សាបង្កើតសមាគម ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលជាសកម្មភាពបន្តពីឆ្នាំ ២០១១ មក។ បន្ទាប់ពីការពិភាក្សាជាបន្តបន្ទាប់ មហាសន្និបាតលើកទីមួយដើម្បីបង្កើតក្រុមប្រឹក្សារាជធានី ខេត្តបានប្រារព្ធឡើងនៅរាជធានីភ្នំពេញនាថ្ងៃទី២៧-២៨ ខែមីនា ឆ្នាំ ២០១៣។ ដូច្នេះ បច្ចុប្បន្ន យើងមានសមាគមពីរ គឺសមាគមឃុំ សង្កាត់ដែលបង្កើតឡើងតាំងពីឆ្នាំ២០០៦ និងសមាគមរាជធានី ខេត្តដែលទើបតែបង្កើតឡើងនេះ។ រីឯក្រុមប្រឹក្សា ស្រុក ខណ្ឌ កំពុងស្ថិតនៅក្នុងការពិចារណាបញ្ចូលទៅក្នុងសមាគមមួយខាងលើ។

## ៨.៤ ការផ្ដោតលើការផ្ដល់សេវាសង្គមក្នុងអាណត្តិទីបីរបស់ឃុំ សង្កាត់

មូលនិធិឃុំ សង្កាត់ដើរតួនាទីសំខាន់ ក្នុងដំណើរការកំណែទម្រង់នៅថ្នាក់មូលដ្ឋាន។ មូលនិធិឃុំ សង្កាត់បានកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ។ មួយភាគបីនៃថវិកា ឃុំ សង្កាត់ត្រូវបានវិភាជន៍សម្រាប់ការងាររដ្ឋបាល និងចំណែកនៅសល់ត្រូវបានប្រើសម្រាប់ការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍ជាអាទិភាពរួមមានដូចជា ហេដ្ឋារចនាសម្ព័ន្ធផ្នែករូបវន្ត និងសេវាសង្គម។ កាលពីមុនថវិកាឃុំ សង្កាត់បានចំណាយភាគច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធផ្នែករូបវន្ត។ ប៉ុន្តែចាប់ផ្ដើមពីឆ្នាំ ២០១២មក ឃុំ សង្កាត់ភាគច្រើន បានវិភាជន៍មូលនិធិឃុំ សង្កាត់ និងធនធានដែលបានមកពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ទៅលើលើការផ្ដល់សេវាសង្គមរួមមាន មតេយ្យសហគមន៍ អនាម័យទឹកស្អាត សុខភាពមាតា និងទារក អាហារូបត្ថម្ភ កិច្ចការពារកុមារ គ្រួសារងាយទទួលរងគ្រោះ និងការចុះសំបុត្រកំណើត។

សេចក្ដីណែនាំស្ដីពីវដ្ដនៃការធ្វើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់រយៈពេលប្រាំឆ្នាំដែលរៀបចំដោយក្រសួងផែនការក្នុងខែមិថុនា ឆ្នាំ ២០១២ បានកាត់ចោលចំណុចមួយក្នុងផ្នែកដែលទាក់ទងនឹងស្ថានភាព និងបញ្ហាប្រឈមរបស់ឃុំ សង្កាត់ មកនៅត្រឹមបួនផ្នែក ហើយបានកំណត់យកបញ្ហាសង្គមជាផ្នែកទីមួយវិញ ដែលពីមុនវាស្ថិតក្នុងលំដាប់ទីពីរបន្ទាប់ពីបញ្ហាសេដ្ឋកិច្ច។

# ៩. សន្និដ្ឋាន និងមេរៀន

១. វិមជ្ឈការក្នុងអាណត្តិទីពីរ បង្ហាញពីការសម្រេចបានច្រើនគួរសមផ្នែកក្របខ័ណ្ឌច្បាប់ និងការផ្ដោតការយកចិត្តទុកដាក់ទៅលើថ្នាក់ស្រុក និងខេត្ត ក្នុងការជួយគាំទ្រឃុំ សង្កាត់។ ការសម្រេចបានរបស់កំណែទម្រង់កន្លងមក បានបង្ហាញពីសក្ដានុពលក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលបង្ហាញឡើងតាមរយៈការកើនឡើងនូវចំណេះដឹងរបស់ប្រជាពលរដ្ឋ អំពីសេរីភាពបញ្ចេញមតិ និងការចូលរួមអង្គការនានា និងទំនាក់ទំនងជិតស្និទ្ធិជាងមុនរវាងរដ្ឋ និងសង្គម។

២. ទោះបីជាវឌ្ឍនភាពនៃកំណែទម្រង់ត្រូវបានគេរកឃើញ វិមជ្ឈការនៅមិនទាន់សម្រេចបានពេញលេញនៅឡើយ។ ខណៈដែលការសម្រេចចិត្ត និងការធ្វើផែនការរបស់ក្រុម

ប្រឹក្សាឃុំ ធ្វើឡើងដោយផ្អែកទៅលើនិតិវិធី ការអនុវត្តការងារបែបថៅហ្វាយនាយ-កូនថៅនៅតែកើតមានឡើង។ ការអនុវត្តនយោបាយពហុបក្សមិនគួរផ្តោតតែទៅលើថ្នាក់ឃុំនោះទេ គឺត្រូវផ្តោតទៅលើថ្នាក់ភូមិផងដែរ។ គេគួរតែធ្វើការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងរវាងគណបក្សនយោបាយក្នុងដំណើរការនៃការជ្រើសរើសមេភូមិ។

៣. គោលការណ៍ជាគន្លឹះនៃវិមជ្ឈការហិរញ្ញវត្ថុ គឺថាហិរញ្ញវត្ថុគួរតែមកស្របជាមួយនឹងមុខងារ នេះមានន័យថា នៅពេលដែលមុខងារត្រូវគេផ្ទេរមកថ្នាក់ក្រោម ធនធានហិរញ្ញវត្ថុក៏គួរត្រូវបានគេផ្តល់ផងដែរដើម្បីធានាថាមុខងារត្រូវបានគេអនុវត្តបានល្អប្រសើរ។ ខណៈដែលការផ្ទេរហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ បរិមាណថវិការបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ នៅមិនទាន់គ្រប់គ្រាន់សម្រាប់ឲ្យក្រុមប្រឹក្សាឃុំ ឆ្លើយតបនឹងតម្រូវការមូលដ្ឋានឡើយ។ ការលើកកម្ពស់ការផ្ទេរហិរញ្ញវត្ថុទៅឲ្យក្រុមប្រឹក្សាឃុំ/សង្កាត់គឺនៅតែជាចំណុចអាទិភាព ដើម្បីជម្រុញឲ្យមានគណនេយ្យភាពទៅកាន់ប្រជាពលរដ្ឋ។

៤. ខណៈដែលការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំពាក់ព័ន្ធនឹងការអនុវត្តន៍កម្មវិធីវិនិយោគកំពុងសម្រេចបានយ៉ាងជោគជ័យ ក្រុមប្រឹក្សាឃុំពុំទាន់មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងកិច្ចការពារធនធានធម្មជាតិនៅឡើយទេ។ ក្រុមប្រឹក្សាឃុំមិនមានអំណាចក្នុងការផ្លាស់ប្តូរ ឬមានឥទ្ធិពលចំពោះ ការសម្រេចចិត្តលើបញ្ហាធំៗពាក់ព័ន្ធនឹងធនធានធម្មជាតិនៅក្នុងឃុំរបស់ខ្លួន។ ការធ្វើអន្តរាគមន៍របស់ក្រុមប្រឹក្សាឃុំតែងតែបង្កឲ្យមានផលខាតបង់ដល់ខ្លួនឯង។ វិមជ្ឈការដែលមានបំណងពង្រឹងការសម្រេចចិត្តថ្នាក់មូលដ្ឋាន ខ្វះភាពពិភាក្សាឲ្យបានច្បាស់លាស់ពាក់ព័ន្ធនឹងថា តើក្រុមប្រឹក្សាឃុំគួរដោះស្រាយបញ្ហាធនធានធម្មជាតិដែលកើតឡើងក្នុងដែនរបស់ខ្លួនរបៀបណា ដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

៥. ផ្អែកតាមទ្រឹស្តី វិមជ្ឈការអាចដំណើរការបានល្អ លុះត្រាតែមានការចូលរួមពីប្រជាពលរដ្ឋ។ តែយើងត្រូវទទួលស្គាល់ថា ប្រជាពលរដ្ឋកម្ពុជានៅមិនទាន់ស៊ាំនឹងការបញ្ចេញមតិទៅកាន់ថ្នាក់ដឹកនាំ លើកលែងករណីចាំបាច់។ នេះទាមទារពេលវេលា និងកិច្ចខិតខំប្រឹងប្រែង។ ទោះជាយ៉ាងណា ក៏ដោយ ត្រូវចងចាំថា ការចូលរួមកើតចេញពីទំនុកចិត្តរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ ទស្សនៈមូលដ្ឋាន និងការលើកទឹកចិត្ត។

៦. ខណៈដែលវិមជ្ឈការបច្ចុប្បន្នឋិតក្នុងដំណាក់កាលនៃការរៀបចំផ្ទេរមុខងារ ឆន្ទៈនយោបាយនៅថ្នាក់ក្រសួងគឺសំខាន់ ជាពិសេសក្នុងការកំណត់មុខងារសមស្របដើម្បីផ្ទេរទៅឲ្យថ្នាក់ស្រុក ក្រុង/ថ្នាក់ក្រោមជាតិ។

៧. ការបណ្តុះបណ្តាលសមត្ថភាពសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាចំណុចសំខាន់ ជាពិសេសក្រុមប្រឹក្សាដែលទទួលខុសត្រូវក្នុងគណៈកម្មាធិការស្ត្រី និងកុមារ។ ការបណ្តុះបណ្តាលក៏គួរផ្តល់ផងដែរដល់ក្រុមប្រឹក្សាថ្នាក់ស្រុក ក្រុង និងខេត្ត ដើម្បីចៀសវាងការពឹងផ្អែកទៅលើគណៈអភិបាល។ ការបញ្ជាក់ទៅលើអត្តសញ្ញាណ និងមុខងារក៏មានសារៈសំខាន់សម្រាប់ការអនុវត្តន៍តួនាទី ជាពិសេសទាក់ទងនឹងការធ្វើផែនការ និងថវិកា។

៨. តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល មានសារៈសំខាន់ដើម្បីជួយពន្លឿនដំណើរការវិមជ្ឈការ។ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល អាចរួមចំណែកលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ ពង្រឹងការចូលរួម និងគណនេយ្យភាពសង្គម និងធ្វើជាប្រព័ន្ធគាំទ្រដល់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំក្នុងពេលចាំបាច់។

# ឧបសម្ព័ន្ធ ក៖ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

| ឆ្នាំ | ឈ្មោះច្បាប់ និងគោលនយោបាយ | គោលបំនង |
|---|---|---|
| ២០០៧ | សេចក្តីណែនាំស្តីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ | សេចក្តីណែនាំនេះកំណត់ពីសមាសភាពរបស់គណៈកម្មការ និងតួនាទីរបស់ក្រុមប្រឹក្សាឃុំ និងសមាជិក |
| ២០០៨ | ព្រះរាជក្រឹត្យស្តីពីបង្កើតគណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍន៍ប្រកបដោយប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) | (គ.ជ.អ.ប) បង្កើតឡើងដើម្បីសម្របសម្រួល និងដឹកនាំការអនុវត្តច្បាប់ស្តីពីការរៀបចំរដ្ឋបាលរាជធានីខេត្ត ក្រុងស្រុក ខណ្ឌ និងច្បាប់ស្តីពីការរៀបចំរដ្ឋបាលឃុំ សង្កាត់ |
| ២០០៨ | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | ច្បាប់នេះមានគោលបំណងកំណត់ពីគោលការណ៍គ្រឹះក្នុងការរៀបចំប្រព័ន្ធហិរញ្ញវត្ថុទូទៅ និងការបង្កើតច្បាប់ហិរញ្ញវត្ថុ ជាពិសេសផ្តោតលើជំហាន នៃការរៀបចំថវិកា ការអនុម័ត និងការអនុវត្តន៍ថវិកា ការត្រួតពិនិត្យដំណើរការថវិកា ការកំណត់តួនាទី និងផលវិបាកក្នុងការធ្វើខុសពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធ ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងស្ថាប័ន គ្រឹស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២០០៨ | សេចក្តីសម្រេចស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ | សេចក្តីសម្រេចនេះមានគោលបំណងសាកល្បងបង្កើតយន្តការក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាពលរដ្ឋដោយប្រើប្រាស់នីតិវិធីសាមញ្ញ មានតម្លាភាព រយៈពេលរហ័ស ពីកន្លែងច្រកចេញចូលតែមួយនៅថ្នាក់ ស្រុក ខណ្ឌ |
| ២០០៨ | ច្បាប់ស្តីពីការរៀបចំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ច្បាប់នេះកំនត់ពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| ២០០៨ | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខ័ណ្ឌ | គោលបំណងនៃច្បាប់នេះចែងពីការរៀបចំ រដ្ឋបាល និងការបង្កើតឲ្យមានការបោះឆ្នោតមិនផ្ទាល់ក្នុងការជ្រើស រើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ |
| ២០០៩ | អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់លេខាធិការដ្ឋាន គ.ជ.អ.ប | លេខាធិការដ្ឋានគ.ជ.អ.ប បង្កើតឡើងដើម្បីអនុវត្តច្បាប់ ស្តីពីការការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ |
| ២០០៩ | អនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | គោលបំណងនៃអនុក្រឹត្យនេះគឺកំណត់ពីគោលនយោបាយយន្តការ និងនីតិវិធីក្នុងការពិភាក្សាស្តីពីការបង្កើត ការរៀបចំ និងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិដូចដែលបានកំណត់ក្នុងមាត្រា ៣៨ ៣៩ នៃច្បាប់ស្តីពីការរៀបចំការចាត់ចែងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |

| | | |
|---|---|---|
| ២០០៩ | ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ប្រកាសនេះមានគោលបំណងកំណត់ពីការបង្កើត និងការកំណត់មុខងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី នឹងកុមារក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងចែងពីតួនាទីរបស់ក្រុមប្រឹក្សា |
| ២០១០ | សេចក្តីណែនាំស្តីពីការអនុវត្តន៍មុខងាររបស់គណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអភិវឌ្ឍន៍ ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សា សហគមន៍ អនាម័យ សមភាព យេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់ | សេចក្តីណែនាំនេះបង្កើតឡើងដើម្បីជួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ក្នុងការអនុវត្តន៍ពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សា សហគមន៍ អនាម័យ សមភាព យេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់ |
| ២០១០ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (2010-2019) | កម្មវិធីនេះ ផ្តល់នូវក្របខ័ណ្ឌសម្រាប់អនុវត្ត ផ្តល់ការណែនាំពីផែនការរបស់គ.ជ.អ.ប លេខាធិការដ្ឋាន និងភាគី ដែលពាក់ព័ន្ធផ្សេងទៀត |
| ២០១០ | ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព | គោលនយោបាយភូមិ ឃុំមានសុវត្ថិភាពមានគោល បំណងក្នុងការបង្កើត និងពង្រឹងសន្តិភាព និងសុវត្ថិភាព តាមរយៈការលុបបំបាត់គ្រប់ប្រភេទបទល្មើសក្នុងភូមិ និងឃុំ សង្កាត់ និងជម្រុញឲ្យមានការសហការ និងចូលរួមពីអាជ្ញាធរមានសមត្ថកិច្ចទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ វិស័យឯកជន និងប្រជាជនទាំងអស់រួមគ្នាបង្កើនជាកម្លាំង យន្តការ និងមធ្យោបាយរួម |
| ២០១០ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូងនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ | ផែនការនេះមានមុខងារ ផ្តោតពិសេសលើការកសាងសមត្ថភាពស្រុក និងក្រុង ឃុំ សង្កាត់ដើម្បីឲ្យគេអាចធ្វើជាតំណាងប្រជាពលរដ្ឋមូលដ្ឋាន និងដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន |
| ២០១១ | ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការរៀបចំទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ | ច្បាប់នេះមានគោលបំណងបង្កើតនូវប្រភពធនធានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់នូវសមត្ថភាពគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍ដោយចិរភាពតាមបែបប្រជាធិបតេយ្យ និងពង្រឹងការអនុវត្តគោល នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ |
| ២០១២ | អនុក្រឹត្យស្តីពីដំណើរការទូទៅក្នុងការផ្ទេរមុខងារនិងធនធានទៅកាន់រដ្ឋ | អនុក្រឹត្យនេះមានគោលបំណង ផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិទៅកាន់រដ្ឋបាលថ្នាក់ ក្រោមជាតិ ដើម្បីលើក |

| | | |
|---|---|---|
| | បាលថ្នាក់ក្រោមជាតិ | កម្ពស់ ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍ |
| ២០១២ | សេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ | គោលបំណងចម្បងក្នុងការរៀបចំបញ្ជីវិភាគមុខងារ គឺដើម្បីបង្កើតមូលដ្ឋានសម្រាប់ការប្រគល់មុខងាររបស់ថ្នាក់ជាតិ ស្ថាប័ន មន្ទីរ ការិយាល័យ និងអាជ្ញាធរមានសមត្ថកិច្ច គ្រប់លំដាប់ថ្នាក់ |
| ២០១២ | អនុក្រឹត្យស្តីពីមូលនិធិក្រុង ស្រុក | អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំ និងកំណត់មុខងាររបស់ មូលនិធិស្រុក ក្រុងដូចដែលបានបង្កើតឡើងដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

# ឧបសម្ព័ន្ធ ខ៖ ឯកសារយោង

ADB (2011). Deconcentration and Decentralization Reforms in Cambodia Recommendations for an Institutional Framework, ADB.

Ann, S. (2008). Patron-clientelism and decentrlizaiton: An empitical local poltical culture in rural Cambodia., Northern Illinois University. **MA thesis**

Blunt, P. and M. Turner (2005). Decentralization, democracy and development in a Post-Conflict Society: Commune Councils in Cambodia, Public Administration and Development**:** p25, p 75-87.

Chheat, S., P. Lun, et al. (2011). A Baseline survey of sub-national governments: Towards a better understanding of decentralization and deconcentration reform in Cambodia Phonom Penh, CDRI.

COMFREL (2007). Assessment of the First term of Decentralization in Cambodia: Commune Council Performance and Citizen's Participation, 2002-2007, COMFREL.

COMFREL (2011). Survey on local participation and democratic governance. Phnom Penh, COMFREL.

COMFREL (2013). Summary report on result of citizen's score card on elected officialsto respond to the priority needs at remote or indigenous communes, COMFREL.

Craig, D. and K. Pak (2011). Party financing of local investment projects: Elite and mass patronage, in Hughes C. & Un Kheang (eds). (Denmark: NIAS, Cambodia’s economic transformation.

EIC (2010). Report of the second citizen satisfaction survey in target communes of the LAAR project. Phnom Penh, EIC.

Heng, S., S. Kim, et al. (2011). Decentralised governance in a hybrid polity: Localisation of decentralization reform in Cambodia. Phnom Penh, CDRI.

Kim, S. (2011). Democracy in action: Decentralization in Post-Conflict Cambodia., Goterborg University.

Kim, S. and J. Ojendal (2007). Where decentralisation meets democracy: civil society, local governance and accountability in Cambodia. Phnom Penh, CDRI.

Kim, S. and J. Öjendal (2007). Where decentralization meets democracy: Civil society, local government, and accountability in Cambodia. Phnom Penh, CDRI.

Kim, S. and J. Öjendal (2009). Decentralization as a strategy for state reconstruction in Cambodia, in J. Öjendal & M. Lija (eds). Beyond democracy in Cambodia: Political reconstruction in a Post-conflict society p.101-135.

Malena, C. and K. Chhim (2009). Linking citizens and the state: An assessment of civil society contributions to good governance in Cambodia, World Bank.

Meerkerrk, D., S. Hean, et al. (2008). Survey of Citizen and Councilor Perceptions of Commune Councils, USAID and PACT Cambodia.

MoI and Unicef (2009). Capacity Assessment for the CCWC. Phnom Penh.

NCDD (2011). Report on the achievement on the implementation of commune/sangkat council in second term (2007-2011). Phnom Penh, NCDD.

NCDD (2012). Report on the achievements of 3-year Implementation Plain (IP3) in the 1st quarter. Phnom Penh, NCDD.

NCDD (Forthcoming). Mid Term Review of the Implementation Plan 2011-13 (IP-3) (draft). Phnom Penh, NCDD.

Öjendal, J. and S. Kim (2011). Real democratization in Cambodia? An empirical review of the potential of a decentralization reform. Sweden, ICLD.

Pak, K. (2011). Fical Decentralisation in Cambodia: A review of Progress and Challenges. Phnom Penh, CDRI.

Plummer, J. and G. Tritt (2011). Voice, Choice and Decision: A Study of Local Governance Processes in Cambodia, World Bank.

RGC (2009). Commune/Sangkat fund project implementation manual. Phnom Penh, RGC.

Schedler, A. (1999). Conceptualizing accountability.

TAF (2011). Safer communities in Cambodia: Partnership between AusAID and the Asia Foundation. Phnom Penh, TAF.

Thon, V., S. Ou, et al. (2009). Leadership in local politics of Cambodia: A study of leaders in three communes of three provinces. Phnom Penh, CDRI.